# ផែនការសកម្មភាពអាសន្ន

ឈ្មោះអាជីវកម្មនៅត្រង់នេះ

ឆ្នាំ2025

# សេចក្តីបដិសេធទំនួលខុសត្រូវ

ផែនការសកម្មភាពអាសន្ននេះ ត្រូវបានអភិវឌ្ឍឡើងដោយទីភ្នាក់ងារគ្រប់គ្រងអាសន្នក្រុងប្រូវីដេន (PEMA)
ដើម្បីជួយអាជីវកម្មទាំងឡាយបង្កើតនូវភាពរួចរាល់គ្រប់ជ្រុងជ្រោយទល់នឹងគ្រោះមហន្តរាយ ការឆ្លើយតប និងកម្មវិធីស្តារឡើងវិញ។ គំរូនេះ គឺជាគំរូទីមួយនៅក្នុងធូលឃីតបន្តអាជីវកម្ម ហើយវាមានបញ្ចូលនូវធាតុផ្សេងៗរបស់ផែនការសកម្មភាពអាសន្ន។ ទោះជាយ៉ាងណាក៏ដោយ អាជីវកម្មគួរតែបំពេញនូវគំរូដែលអាចប្តូរតាមបំណងបាននេះ ឲ្យត្រូវគ្នាជាមួយនឹងដំណើរការ ប្រតិបត្តិការ និងតម្រូវការដាច់ដោយឡែករបស់ខ្លួន។ ការកែតម្រូវលើសពីអ្វីដែលបានស្នើក្នុងវង់ក្រចក អាចត្រូវបានទាមទារដើម្បីបង្កើតកម្មវិធីដែលមានប្រសិទ្ធភាព និងសមស្រប។

ផែនការនេះ មិនមានបំណងជំនួសច្បាប់ បទប្បញ្ញត្តិ ស្តង់ដារ ឬតម្រូវការOSHA ដែលអនុវត្តចំពោះអាជីវកម្ម ឬកន្លែងរបស់អ្នកទេ។ ផែនការនេះ មិនមែនជាការជំនួសបទប្បញ្ញត្តិ ក្នុងមូលដ្ឋាន រដ្ឋ ឬសហព័ន្ធទេ ហើយក៏មិនជំនួសស្តង់ដារឧស្សាហកម្មដែរ។ វាគួរតែត្រូវបានប្រើដោយភ្ជាប់ជាមួយនឹងតម្រូវការច្បាប់ និងបទប្បញ្ញត្តិដែលអាចអនុវត្តបានទាំងអស់។

*ផ្តល់ជូនជាសេវាកម្មសាធារណៈដោយទីភ្នាក់ងារគ្រប់គ្រងអាសន្នក្រុងប្រូវីដេន (PEMA)*


**PROVIDENCE EMERGENCY MANAGEMENT AGENCY**
591 Charles Street | 401-680-8000
www.providenceri.gov/PEMA

# មាតិកា


## 1. ផែនការសកម្មភាពអាសន្ន 5

ការបែងចែកទំនួលខុសត្រូវ 5
ការដាក់ផែនការឲ្យដំណើរការ 7
នីតិវិធីទាក់ទង 7
ផែនការជម្លៀស 9
ជម្រកនៅនឹងកន្លែង 11
ការធានាទ្រព្យសម្បត្តិនិងឧបករណ៍ 14
ការបណ្តុះបណ្តាល 15

## 2. ការណែនាំពីការឆ្លើយតបអាសន្ន 16

ស្ថានភាពវេជ្ជសាស្ត្រ 16
ភ្នាក់ងារបង្ករោគក្នុងឈាម 18
អាកាសធាតុអាក្រក់ខ្លាំង 20
អគ្គិភ័យ 24
អំពើហិង្សានៅកន្លែងការងារ 27
ការលួចប្លន់ 28
កង្វក់ផលិតផល 28
ទឹកជំនន់ 29
ការកំពប់សាំងនិងសារធាតុគីមី 35
ការលេចធ្លាយឧស្ម័ននិងប្រូប៉ែនធម្មជាតិ 37
សារធាតុសង្ស័យ (កញ្ចប់ និង សំបុត្រ) 38
ចលាចលស៊ីវិល 40
ការគំរាមបំផ្ទុះគ្រាប់បែក 41
ការដាច់ភ្លើង 42
កង្វក់ទឹក និង ការផ្តល់យោបល់ពីការដាំទឹក 43
ការបែកបំពង់ទឹក 45
ការដាច់ប្រព័ន្ធក្លាសេ និង សុវត្ថិភាពអាហារ 47

## 3. ឧបសម្ព័ន្ធ 51

ឧបសម្ព័ន្ធA – ផែនការផ្លូវជម្លៀសចេញពីកន្លែង 51
ឧបសម្ព័ន្ធB – សេវាកម្មអាសន្នសាធារណៈនិងអ្នកម៉ៅការ 52
ឧបសម្ព័ន្ធC – ក្រុមការងារឆ្លើយតបអាសន្ន (ERT) 53
ឧបសម្ព័ន្ធD – បញ្ជីពិនិត្យការគំរាមបំផ្ទុះគ្រាប់បែក 55
ឧបសម្ព័ន្ធE – បញ្ជីពិនិត្យផែនការសកម្មភាពអាសន្ន ផ្តល់ដោយOSHA 56
ឧបសម្ព័ន្ធF – ការចែកចាយផែនការ និង ប្រវត្តិនៃការកែសម្រួល 63

# 1. ផែនការសកម្មភាពអាសន្ន

ផែនការសកម្មភាពអាសន្ន (EAP)
ណែនាំពីការឆ្លើយតបរបស់ក្រុមហ៊ុនទល់នឹងស្ថានភាពអាសន្នផ្សេងៗដូចជាហេតុការណ៍វេជ្ជសាស្ត្រ អគ្គិភ័យ ទឹកជំនន់ និងការគំរាមសកម្មជាដើម។ ស្ថានភាពទាំងនេះអាចនឹងទាមទារការជម្លៀស ជម្រកនៅនឹងកន្លែង ការធានាទ្រព្យសម្បត្តិនិងឧបករណ៍ និងសកម្មភាពផ្សេងទៀតដើម្បីទប់ស្កាត់ការរងរបួស ការបាត់បង់ជីវិត ឬការខូចខាតទ្រព្យសម្បត្តិ។

## ការបែងចែកទំនួលខុសត្រូវ

### អ្នកគ្រប់គ្រងផែនការអាសន្ន

បើមានការរំខានអាជីវកម្មណាមួយ **(ឈ្មោះ)** នឹងត្រូវបានទាក់ទងដើម្បីដាក់ផែនការឲ្យដំណើរការ។ សម្រាប់គោលបំណងរបស់ផែនការនេះ ការរំខានអាជីវកម្មត្រូវបានកំណត់និយមន័យថាជា៖

1. ការរំខានធ្ងន់ធ្ងរ ឬ ការគំរាមលើដំណើរការ ឬ
2. ស្ថានភាពអាសន្នភ្លាមៗឬជិតមកដល់ ដែលរំពឹងថានឹងមានឥទ្ធិពលលើអាជីវកម្ម

អ្នកគ្រប់គ្រងផែនការអាសន្ន
ទទួលខុសត្រូវក្នុងការកំណត់កាលវិភាគការធ្វើតេស្តជាប្រចាំនូវប្រព័ន្ធជូនដំណឹងអាសន្ន
ជាមួយអាជ្ញាធរសមស្រប
ហើយក៏ត្រូវបានលើកទឹកចិត្តឲ្យសម្របសម្រួលជាមួយធនធានសាធារណៈក្នុងមូលដ្ឋាន
សម្រាប់ការដើរមើលកន្លែង។

### អ្នកសម្របសម្រួលផែនការអាសន្ន

អ្នកសម្របសម្រួលផែនការអាសន្ន
ទទួលខុសត្រូវក្នុងការអនុវត្តនីតិវិធីនៅក្នុងផែនការនេះក្នុងតំបន់ដែលបានកំណត់របស់ពួកគេក្នុងគ្រាអាសន្ន។ *(ឧទាហរណ៍៖ អ្នកសម្របសម្រួល អាចត្រូវបានផ្តល់ការទទួលខុសត្រូវក្នុងការកត់បញ្ជីបុគ្គលិក ឬភ្ញៀវក្រោយពីការជម្លៀស។)*

| ឈ្មោះ | ផ្នែក / នាយកដ្ឋាន | លេខទូរសព្ទ | ឈ្មោះជំនួស | លេខទូរសព្ទជំនួស |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

បុគ្គលខាងក្រោមនេះ នឹងត្រូវទទួលខុសត្រូវក្នុងការជួយបុគ្គលិកដែលមានពិការភាព ឬដែលមិនចេះនិយាយភាសាអង់គ្លេស នៅពេលជម្លៀស។

| ឈ្មោះ | ផ្នែក / នាយកដ្ឋាន | ភាសាដែលចេះនិយាយ | លេខទូរសព្ទ | លេខទូរសព្ទជំនួស |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |

# ការដាក់ផែនការឲ្យដំណើរការ

ចំពោះស្ថានភាពអាសន្នដែលគំរាមដល់អាយុជីវិតឬទ្រព្យសម្បត្តិ ជាដំបូង បុគ្គលិកគួរតែហៅទូរសព្ទទៅលេខ9-1-1។ បើមានការរំខានអាជីវកម្មណាមួយ **[អាជ្ញាធរផ្ដល់ការអនុញ្ញាត]**នឹងត្រូវបានទាក់ទងដើម្បីដាក់ផែនការឲ្យដំណើរការ។ សម្រាប់គោលបំណងរបស់ផែនការនេះ ការរំខានអាជីវកម្មត្រូវបានកំណត់និយមន័យថាជា៖

1. ការរំខានធ្ងន់ធ្ងរ ឬ ការគំរាមលើដំណើរការ ឬ
2. ស្ថានភាពអាសន្នភ្លាមៗឬជិតមកដល់ ដែលរំពឹងថានឹងមានឥទ្ធិពលលើអាជីវកម្ម
3. **[បញ្ចូលហេតុបន្ថែមដែលនាំទៅរកផែនការ ដែលពាក់ព័ន្ធនឹងអាជីវកម្ម]**

# នីតិវិធីទាក់ទង

ប្រើប្រព័ន្ធខាងក្រោមនេះ ដើម្បីធានាបាននូវការទាក់ទងដែលចាំបាច់ នៅពេលមានស្ថានភាពអាសន្ន ឬនៅពេលមានការរំខាន។

## ការរកឃើញហេតុការណ៍ និង ការរាយការណ៍

- **រាយការណ៍ស្ថានភាពអាសន្ន៖** ទាក់ទងទៅលេខ9-1-1 ភ្លាមៗ ចំពោះស្ថានភាពអាសន្នដូចជាអគ្គិភ័យ ហេតុការណ៍វេជ្ជសាស្ត្រ ឬស្ថានភាពគំរាមដល់អាយុជីវិត។ ធានាថាអ្នកឆ្លើយតបបឋម ត្រូវបានជូនដំណឹងភ្លាមៗដោយគ្មានការពន្យារពេល។
- **ជូនដំណឹងបុគ្គលិក៖** ប្រាប់បុគ្គលិកពីស្ថានភាពអាសន្ននានា ទាំងក្នុងនិងក្រៅម៉ោងធ្វើការ។ វារួមបញ្ចូលនូវការធ្វើបច្ចុប្បន្នភាពស្ថានភាពការងារ ជំហានបន្ទាប់ និងដំបូន្មានសុវត្ថិភាព។ ប្រព័ន្ធព្រមាននិងជូនដំណឹង មាននៅខាងក្រោម។
- **ស្ថានភាពអាសន្នប្រភេទថ្មី៖** បើមានការរំខានផ្នែកIT បញ្ហាខ្សែសង្វាក់ផ្គត់ផ្គង់ ហេតុការណ៍ក្នុងតំបន់មូលដ្ឋាន ត្រូវជូនដំណឹងសមាជិកក្រុមការងារដែលពាក់ព័ន្ធ អ្នកគ្រប់គ្រង និងបុគ្គលពាក់ព័ន្ធ ដើម្បីសម្របសម្រួលការព្យាយាមឆ្លើយតប។

## ប្រព័ន្ធព្រមាននិងជូនដំណឹង

ប្រព័ន្ធខាងក្រោមនេះ ត្រូវបានប្រើដើម្បីព្រមានបុគ្គលិកឲ្យធ្វើសកម្មភាពការពារខ្លួន (ឧទាហរណ៍៖ ជម្លៀសផ្លាស់ទីទៅជម្រកពីព្យុះកំបុតត្បូង ជម្រកនៅនឹងកន្លែង ឬបិទខ្ទប់) និងដើម្បីផ្តល់ព័ត៌មានទៅឲ្យពួកគេ។

| | ប្រព័ន្ធ | ទីតាំង |
|---|---|---|
| **ប្រព័ន្ធព្រមាន** | កណ្តឹងរោទ៍អគ្គិភ័យ | |
| | ផ្តល់ដំណឹងសាធារណៈ | |
| | ផ្សេងទៀត **(រៀបរាប់)** | |

| ប្រព័ន្ធជូនដំណឹង | អេឡិចត្រូនិច | |
|---|---|---|
| | មេកផាងហៅទូរសព្ទ | |
| | ផ្សេងទៀត **(រៀបរាប់)** | |

## ការផ្ញើសារព្រមាននិងជូនដំណឹង

ប្រើគំរូខាងក្រោមនេះ ដើម្បីធានាបានថាការធ្វើបច្ចុប្បន្នភាពដែលច្បាស់លាស់និងជាប់លាប់ត្រូវបានចែករំលែកនៅពេលស្ថានភាពអាសន្នកើតឡើង។ ប្រើប្រព័ន្ធព្រមាននិងជូនដំណឹងដែលមានព័ត៌មានលម្អិតខាងលើ ដើម្បីផ្សព្វផ្សាយការផ្ញើសារដែលមានបង្ហាញខាងក្រោម។

| |
|---|
| បុគ្គលិកនិងអតិថិជនទាំងអស់ សូមស្តាប់យ៉ាងយកចិត្តទុកដាក់។ នេះជាការប្រកាសអាសន្ន។<br><br>[បញ្ចូលស្ថានភាពអាសន្ន] ត្រូវបានរាយការណ៍ថាមាននៅ[បញ្ចូលទីតាំង]។ ដើម្បីសុវត្ថិភាពរបស់អ្នក [បញ្ចូលសកម្មភាពសមស្របៈ ជម្លៀស ជម្រកនៅនឹងកន្លែង ជាដើម] ភ្លាមៗ។<br><br>[បញ្ចូលដំបូន្មានបន្ថែម]<br>អ្នកឆ្លើយតបអាសន្ន កំពុងធ្វើដំណើរមក។ ធ្វើតាមគ្រប់ដំបូន្មានរបស់មន្ត្រី ហើយទៅកាន់[តំបន់សុវត្ថិភាពដែលបានកំណត់]។ រក្សាភាពស្ងប់ស្ងៀម និងជួយអ្នកផ្សេងផងបើចាំបាច់។ |

## ផែនការជម្លៀស

បើមានពួកណ្តឹងរោទ៍អាសន្ន ឬមានការផ្តល់ដំបូន្មានឲ្យជម្លៀស បុគ្គលិកត្រូវតែចេញពីអគារភ្លាមៗ ហើយជួបគ្នានៅ **(តំបន់ជួបជុំដែលបានកំណត់)**។

- ផែនការផ្លូវរត់គេចជម្លៀសអាសន្ន (មើលឧបសម្ព័ន្ធA) ត្រូវបានបិទបង្ហាញនៅក្នុង **(តំបន់ដែលបានកំណត់នៅកន្លែងទាំងមូល)**។
- បុគ្គលិកដែលពិបាកចល័តខ្លួន ឬជំនួយការដែលត្រូវបានចាត់តាំងរបស់ពួកគេ នឹងប្រមូលផ្តុំគ្នានៅ **(តំបន់ដែលបានកំណត់)** នៅក្នុងអគារ ដើម្បីធានាបាននូវសុវត្ថិភាព។
- បុគ្គលិកនឹងនាំផ្លូវអតិថិជនដែលនៅជិតពួកគេ ទៅកាន់ច្រកចេញអាសន្នដែលនៅជិតបំផុត នៅពេលពួកគេជម្លៀសចេញពីកន្លែង។
- **គ្មាននរណាម្នាក់ត្រូវបានអនុញ្ញាតឲ្យចូលអគារម្តងទៀតទេ** ក្រោយពីជម្លៀសរួចលុះត្រាតែអនុញ្ញាតដោយអ្នកឆ្លើយតបអាសន្ន។

| | |
|---|---|
| បុគ្គលិកនឹងត្រូវបានព្រមានឲ្យជម្លៀសចេញពីអគារ ដោយប្រើប្រព័ន្ធខាងក្រោម៖ | |
| បុគ្គលិកគួរតែជួបជុំនៅទីតាំងខាងក្រោមដើម្បីកត់បញ្ជីក្រោយជម្លៀស៖ | |







## <u>ការកត់បញ្ជីបុគ្គលិកឬភ្ញៀវ ក្រោយពីជម្លៀស</u>

នៅពេលមានការជម្លៀស **(បុគ្គលទទួលខុសត្រូវ)**នឹងកត់បញ្ជីបុគ្គលិកឬភ្ញៀវគ្រប់រូប ដែលត្រូវបានចាត់តាំងឲ្យពួកគេកត់បញ្ជីនៅ **(តំបន់ជួបជុំដែលបានកំណត់)**។ បុគ្គលិកគ្រប់រូប ទទួលខុសត្រូវក្នុងការរាយការណ៍ទៅកាន់**(បុគ្គលទទួលខុសត្រូវ)**សមស្រប ដើម្បីឲ្យអាចរាប់ចំនួនមនុស្សបានត្រឹមត្រូវ។ បន្ទាប់ពីនោះ ការរាប់របស់បុគ្គលិកទាំងអស់ នឹងត្រូវបានរាយការណ៍ទៅកាន់ **(អ្នកគ្រប់គ្រងផែនការសកម្មភាពអាសន្ន)** ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

| | |
|---|---|
| បុគ្គលដែលនឹងយកបញ្ជីឈ្មោះបុគ្គលិក និងកំណត់ហេតុភ្ញៀវ ទៅកាន់តំបន់ជួបជុំជម្លៀស ដែលនឹងត្រូវកត់បញ្ជីអ្នកជម្លៀសទាំងអស់៖ | |

## ជម្រកនៅនឹងកន្លែង

ក្នុងស្ថានភាពអាសន្នជាក់លាក់មួយចំនួន ដូចជាអាកាសធាតុអាក្រក់ខ្លាំង ការបញ្ចេញសារធាតុអន្តរាយ ឬចលាចលស៊ីវិល នោះជម្រកនៅនឹងកន្លែងអាចនឹងត្រូវបានទាមទារ។ នៅពេលដែលនៅខាងក្នុងមានសុវត្ថិភាពជាងជម្លៀស នឹងមានការប្រកាសពីជម្រកនៅនឹងកន្លែង តាមរយៈប្រព័ន្ធព្រមាននិងជូនដំណឹងដែលត្រូវបានបញ្ជាក់មុននេះ។

| ការចាត់ចែង | ឈ្មោះ / មធ្យោបាយទាក់ទង |
|---|---|
| ប្រធានក្រុម៖ | |
| បុគ្គលដែលនឹងតាមដានអាកាសធាតុឬប្រភពព័ត៌មាន<br>ដើម្បីទទួលបានដំបូន្មានអាសន្នដែលត្រូវបានធ្វើបច្ចុប្បន្នភាព និងការផ្សព្វផ្សាយព្រមាន៖ | |

| | |
|---|---|
| បុគ្គលដែលនឹងធានាថាតំបន់ជម្រកមានស្តុកសម្ភារផ្គត់ផ្គង់អាសន្ន៖<br>1. កញ្ចប់សង្គ្រោះបឋម<br>2. ពិលនិងថ្មពិល<br>3. បញ្ជីមធ្យោបាយទាក់ទងអាសន្ន<br>4. វិទ្យុដែលប្រើថ្មពិល<br>5. ទឹក និងអាហារសម្រន់ដែលមិនឆាប់ខូច<br><br>សម្ភារផ្គត់ផ្គង់ នឹងត្រូវបានស្តុករួមគ្នានៅក្នុង **(បញ្ចូលទីតាំង/បន្ទប់/ទូ)**។ សម្ភារផ្គត់ផ្គង់នឹងត្រូវបានយកទៅ **(តំបន់ជម្រកដែលបានកំណត់)** នៅពេលចូលជម្រក។ | |
| បុគ្គលដែលនឹងផ្តាច់ប្រព័ន្ធខ្យល់ចេញចូល និងបិទកុំឲ្យមានខ្យល់ចូល៖ | |
| បុគ្គលដែលនឹងប្រមូលការរាប់ចំនួនមនុស្ស និងសរសេរឈ្មោះ/អង្គភាពរបស់គ្រប់គ្នានៅក្នុងតំបន់ជម្រក៖ | |
| មធ្យោបាយទាក់ទងអាសន្នដែលបានកំណត់នៅក្រៅអគារ៖ | |

| | |
|---|---|
| **ទីតាំងជម្រកនៅនិងកន្លែងដែលបានកំណត់៖** | |

*[ជ្រើសរើសបន្ទប់ខាងក្នុង នៅខាងលើជាន់ផ្ទាល់ដី ដែលមានបង្អួចឬប្រហោងខ្យល់ចេញចូលតិចបំផុត។ បន្ទប់នោះ គួរតែមានលំហគ្រប់គ្រាន់ដើម្បីឲ្យគ្រប់គ្នាអាចអង្គុយបាន។ ជ្រើសរើសបន្ទប់ច្រើន បើចាំបាច់ ដើម្បីកុំឲ្យណែនមនុស្សពេក។ ជម្រើសដែលល្អគឺមានទូដាក់ឥវ៉ាន់ធំ បន្ទប់របស់របរប្រើប្រាស់ ធ្នើដាក់អីវ៉ាន់ និងបន្ទប់ថតចម្លងនិងបន្ទប់សន្និសីទដែលគ្មានបង្អួចខាងក្រៅ។*
*ចៀសវាងការជ្រើសរើសបន្ទប់ដែលមានឧបករណ៍ម៉ាស៊ីន ដូចជាម៉ាស៊ីនផ្លុំខ្យល់ចេញចូលឬបំពង់ជាដើម ដែលប្រហែលជាមិនអាចបិទបាំងពីបរិយាកាសខាងក្រៅបាន។*
*វាជាការប្រសើរបំផុតដែលមានទូរសព្ទខ្សែរឹងនៅក្នុងបន្ទប់ដែលអ្នកជ្រើសរើស។*
*ហៅទូរសព្ទទៅមធ្យោបាយទាក់ទងអាសន្ន*
*ហើយត្រៀមទូរសព្ទឲ្យបានរួចរាល់ប្រសិនបើអ្នកត្រូវការរាយការណ៍ពីស្ថានភាពគំរាមដល់អាយុជីវិត។]*

**នីតិវិធីជម្រកនៅនឹងកន្លែង៖**

1. **ធានានូវអគារ៖** បុគ្គលិក អតិថិជន និងភ្ញៀវទាំងអស់ នឹងផ្លាស់ទីភ្លាមៗទៅកាន់តំបន់ជម្រកនៅក្នុងអគារ។ បុគ្គលដែលបានកំណត់ នឹងបិទភ្ជិតបង្អួច ទ្វារ និងប្រហោងខ្យល់ចេញចូលទាំងអស់ ដោយប្រើថង់គ្របប្លាស្ទិច និងស្កុត។

2. **ការរាយការណ៍ + មធ្យោបាយទាក់ទងអាសន្ន៖** បុគ្គលដែលបានកំណត់ នឹងសរសេរឈ្មោះរបស់គ្រប់គ្នានៅក្នុងបន្ទប់ និងប្រកាសប្រាប់ទៅមធ្យោបាយទាក់ទងអាសន្នដែលបានកំណត់នៅខាងក្រៅដើម្បីរាយការណ៍ថានរណាខ្លះនៅក្នុងបន្ទប់ និងអង្គភាពរបស់ពួកគេ។ (បុគ្គលិក ភ្ញៀវ អតិថិជន)។ បុគ្គលិកនិងអតិថិជន គួរតែទាក់ទងទៅមធ្យោបាយទាក់ទងអាសន្នដើម្បីប្រាប់ពីទីតាំងដែលពួកគេកំពុងតែនៅ និងធានាថាពួកគេមានសុវត្ថិភាព។

3. **នីតិវិធីទាក់ទង៖** តាមដានទូរសព្ទ វិទ្យុ ទូរទស្សន៍ និងការរាយការណ៍តាមអ៊ីនធើណេត ដើម្បីទទួលបានដំបូន្មានបន្ថែមពីអាជ្ញាធរ ដើម្បីកំណត់ថាពេលណាដែលចាកចេញពីអគារបានដោយសុវត្ថិភាព។

4. ក្រោយព្រឹត្តិការណ៍៖ នៅពេលដែលជម្រកនៅនឹងកន្លែងត្រូវបានលុបចោល អ្នកឆ្លើយតបបឋមឬមន្ត្រីមូលដ្ឋាន នឹងទាក់ទងពីសញ្ញាសុវត្ថិភាពពេញលេញ។

បុគ្គលិកគួរតែធ្វើតាមដំបូន្មានដែលគេឲ្យ ថាតើត្រូវត្រលប់ទៅតំបន់ការងារវិញ ឬត្រូវជម្លៀសចេញពីអគារបើស្ថានភាពនៅតែគ្រោះថ្នាក់។

## ការធានាទ្រព្យសម្បត្តិនិងឧបករណ៍

បើចាំបាច់ត្រូវជម្លៀសចេញពីអគារនិងទីធ្លា វត្ថុមួយចំនួនអាចនឹងត្រូវការធានាដើម្បីទប់ស្កាត់មិនឲ្យមានគ្រោះថ្នាក់បន្ថែមទៀតដល់កន្លែង និងមន្ត្រីដែលប្រចាំការ (ដូចជា ធានានូវកំណត់ត្រាសម្ងាត់ឬមិនអាចជំនួសបាន ឬបិទឧបករណ៍ដើម្បីទប់ស្កាត់មិនឲ្យបញ្ចេញសារធាតុអន្តរាយ)។ មានតែបុគ្គលខាងក្រោមនេះប៉ុណ្ណោះដែលគួរតែបន្តនៅក្នុងអគារក្នុងរយៈពេលដែលបានបញ្ជាក់ ដើម្បីធានាទ្រព្យសម្បត្តិនិងឧបករណ៍ដែលពួកគេត្រូវបានចាត់តាំងឲ្យធានា។

| ឈ្មោះ | ទ្រព្យសម្បត្តិឬឧបករណ៍ដែលត្រូវធានា | ទីតាំងរបស់ទ្រព្យសម្បត្តិឬឧបករណ៍ | រយៈពេលប៉ាន់ស្មានដើម្បីបញ្ចប់ដំណើរការសន្តិសុខ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |

បុគ្គលទាំងអស់ដែលនៅក្រោយដើម្បីផ្តាច់ប្រព័ន្ធឬរបស់របរប្រើប្រាស់សំខាន់ៗ ត្រូវតែមានសមត្ថភាពអាចកត់សម្គាល់បានពេលណាដែលត្រូវបោះបង់ដំណើរការឬភារកិច្ច។ នៅពេលដែលទ្រព្យសម្បត្តិ ឬឧបករណ៍ត្រូវបានធានា ឬនៅពេលដែលស្ថានភាពគ្រោះថ្នាក់ពេកមិនអាចនៅបន្ត អ្នកដែលនៅក្រោយត្រូវតែចេញពីអគារតាមផ្លូវរត់គេចដែលនៅជិតបំផុតឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយជួបជាមួយបុគ្គលិកផ្សេងទៀតនៅ**(ទីតាំងជួបជុំដែលបានកំណត់)**។

# ការបណ្ដុះបណ្ដាល

## ការបណ្ដុះបណ្ដាលបុគ្គលិក

បុគ្គលិកទាំងអស់ នឹងទទួលបានដំបូន្មានពីផែនការសកម្មភាពអាសន្ននេះ ជាផ្នែកមួយនៃការតម្រង់ទិសបុគ្គលិកថ្មី។ ត្រូវតែមានការផ្តល់នូវការបណ្ដុះបណ្ដាលបន្ថែមៈ

1. នៅពេលមានការផ្លាស់ប្តូរណាមួយនៅក្នុងផែនការឬនៅក្នុងកន្លែង
2. នៅពេលមានការផ្លាស់ប្តូរក្នុងការទទួលខុសត្រូវរបស់បុគ្គលិកណាម្នាក់ និង
3. មួយឆ្នាំម្តងៗ ក្នុងទម្រង់ជាការបណ្ដុះបណ្ដាលជាថ្មី

## ការហ្វឹកហ្វឺនជម្លៀសអគ្គិភ័យ

ការហ្វឹកហ្វឺនជម្លៀសអគ្គិភ័យ ត្រូវតែធ្វើឡើងយ៉ាងតិចម្តងក្នុងមួយឆ្នាំ និងត្រូវសម្របសម្រួលធ្វើជាមួយប៉ូលីសមូលដ្ឋាននិងនាយកដ្ឋានពន្លត់អគ្គិភ័យ។ ការហ្វឹកហ្វឺនបន្ថែមនឹងត្រូវបានធ្វើឡើង បើទ្រព្យសម្បត្តិរូបីរបស់អាជីវកម្មមានការប្រែប្រួល បើប្រតិបត្តិការមានការប្រែប្រួល ឬបើត្រូវបានយល់ថាចាំបាច់។

## កំណត់ត្រានៃការបណ្ដុះបណ្ដាល

**(បុគ្គលទទួលខុសត្រូវ)**
នឹងរៀបចំជាឯកសារនូវការបណ្ដុះបណ្ដាលទាំងអស់ដែលជាប់ទាក់ទងនឹងផែនការនេះ ហើយរក្សាកំណត់ត្រានៅ**(តំបន់ដែលបានកំណត់)**។

## ការវាយតម្លៃផែនការ

ផែនការសកម្មភាពអាសន្ននេះ ត្រូវតែពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ឬពិនិត្យឡើងវិញទៅតាមការចាំបាច់បើទីតាំងការងារមានការប្រែប្រួល ហើយការពិនិត្យឡើងវិញត្រូវតែធ្វើឡើងដោយ**(បុគ្គលទទួលខុសត្រូវ)**។ ក្រោយការហ្វឹកហ្វឺនអគ្គិភ័យនីមួយៗ **(ជូរគ្រប់គ្រងទទួលខុសត្រូវនិងតំណាងបុគ្គលិក)**នឹងវាយតម្លៃប្រសិទ្ធភាពនៃការហ្វឹកហ្វឺន និងចំណុចខ្សោយនៅក្នុងផែនការ ហើយអនុវត្តនូវការកែលម្អ។

# 2. ការណែនាំពីការឆ្លើយតបអាសន្ន

ទំព័របន្ទាប់ទៅនេះ នឹងលម្អិតពីជំហានសម្រាប់ហេតុការណ៍ជាក់លាក់
ចំពោះគ្រោះថ្នាក់អន្តរាយឬហេតុការណ៍ដែលបានកំណត់។

**ចំណាំ៖** ការណែនាំពីការឆ្លើយតបអាសន្នទាំងនេះ ត្រូវបានផ្តល់ក្នុងទម្រង់ជាការណែនាំនិងជាឯកសារយោង។

សុវត្ថិភាពអាយុជីវិត គឺជាអាទិភាព។ បើអ្នកមិនចាំចំណុចផ្សេងទេ ត្រូវចាំថា – ***ហៅទូរសព្ទរកជំនួយ ជម្លៀស និងកត់បញ្ជីបុគ្គលិកទាំងអស់*** ។

## ស្ថានភាពវេជ្ជសាស្ត្រ

1. **ហៅទូរសព្ទទៅសេវាកម្មវេជ្ជសាស្ត្រអាសន្ន៖** តេទៅលេខ911 ភ្លាមៗ ហើយផ្តល់ព័ត៌មានលម្អិតខាងក្រោម៖
    - ចំនួននិងទីតាំងរបស់ជនរងគ្រោះ
    - លក្ខណៈរបស់របួសឬជំងឺ
    - គ្រោះថ្នាក់អន្តរាយដែលពាក់ព័ន្ធ
    - ផ្លូវចេញចូលដែលនៅជិតបំផុត (ចំណុចចូលបានគ្រាអាសន្ន)
2. **អនុវត្តការសង្គ្រោះបឋម៖** បើអាច ត្រូវផ្តល់ការសង្គ្រោះបឋមដល់អ្នករបួស។
   បញ្ជីនៃមន្ត្រីដែលបានទទួលការបណ្តុះបណ្តាល និងសម្ភារផ្គត់ផ្គង់សង្គ្រោះបឋមដែលមាន
   មានដូចខាងក្រោម។
3. **នាំផ្លូវមន្ត្រីអាសន្ន៖** បើមានសុវត្ថិភាពក្នុងការធ្វើ
   ត្រូវធានាថាមានមនុស្សម្នាក់ជួបជាមួយមន្ត្រីសេវាកម្មវេជ្ជសាស្ត្រអាសន្ននៅខាងក្រៅ
   ហើយជូនពួកគេទៅទីតាំងរបស់ជនរងគ្រោះ។

**<u>មន្ត្រីដែលបានទទួលការបណ្តុះបណ្តាលដើម្បីអនុវត្តការសង្គ្រោះបឋម សង្គ្រោះដង្ហើមនិងបេះដូង(CPR) ឬប្រើឧបករណ៍ឆក់បេះដូងស្វ័យប្រវត្តិ(AED)</u>**

| ឈ្មោះ | ការបណ្តុះបណ្តាល |
|---|---|
| | |

| | |
|---|---|
| | |
| | |
| | |
| | |
| | |
| | |

**<u>ការណែនាំពីឧបករណ៍វេជ្ជសាស្រ្តនិងទីតាំង</u>**

| **ប្រភេទនៃឧបករណ៍វេជ្ជសាស្រ្ត** | **ទីតាំងនៃឧបករណ៍ឆក់បេះដូងស្វ័យប្រវត្តិ(AED)** |
|---|---|
| | |
| | |
| | |

ទីភ្នាក់ងារគ្រប់គ្រងអាសន្នក្រុងប្រូវីដេន (PEMA)
ផ្តល់ជូននូវការបណ្តុះបណ្តាលពីការសង្គ្រោះដង្ហើមនិងបេះដូង(CPR) ការបញ្ឈប់ការហូរឈាម ការគំរាមសកម្ម និងទម្រាំពេលជំនួយមកដល់។ សម្រាប់ព័ត៌មាននៃការបណ្តុះបណ្តាលទាំងនេះ ចូលទៅកាន់

[providenceri.gov/pema](providenceri.gov/pema)។

ចំណាំ៖

- មានតែអ្នកឆ្លើយតបដែលបានទទួលការបណ្តុះបណ្តាលប៉ុណ្ណោះ ដែលគួរផ្តល់ការសង្គ្រោះបឋម។
- កុំផ្លាស់ទីជនរងគ្រោះ លុះត្រាតែជនរងគ្រោះនោះស្ថិតនៅទីតាំងដែលគ្រោះថ្នាក់។
- ទាក់ទងទៅOSHA ឬអង្គភាពបទប្បញ្ញត្តិផ្សេងទៀត

# ភ្នាក់ងារបង្ករោគក្នុងឈាម

ស្ថានភាពឬហេតុការណ៍ណាដែលអាចមានការប៉ះផ្ទាល់នឹងឈាមឬសារធាតុរាវក្នុងខ្លួនមនុស្ស។

## ប្រការប្រុងប្រយ័ត្ន៖

អនុវត្តប្រការប្រុងប្រយ័ត្នជាសកល គ្រប់ពេលដែលត្រូវឆ្លើយតបនឹងហេតុការណ៍ក្នុងឈាម៖

- សន្មតថាឈាមនិងសារធាតុរាវក្នុងខ្លួនទាំងអស់សុទ្ធតែចម្លងជំងឺ ពាក់ឧបករណ៍ការពារផ្ទាល់ខ្លួន (ស្រោមដៃ វ៉ែនតាហែលតឹក ជាដើម) និងប្រើ"ជីឡាវផ្លុំខ្យល់"ការពារនៅពេលផ្លុំខ្យល់សង្គ្រោះ។
- មានតែបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលពីការប្រើប្រាស់យ៉ាងសមស្របនូវឧបករណ៍ការពារផ្ទាល់ខ្លួនប៉ុណ្ណោះ ដែលគួរឆ្លើយតបទៅនឹងហេតុការណ៍។

## នៅពេលត្រូវការសម្អាតឈាម ឬសារធាតុផ្សេងទៀតដែលអាចចម្លងជំងឺ៖

1. ត្រូវតែពាក់ស្រោមដៃជាប់ជានិច្ច។ ប្រើឧបករណ៍ការពារបន្ថែម ដូចជាអៀមការពារ ម៉ាស់ និង/ឬវ៉ែនតាហែលទឹក ទៅតាមហានិភ័យដែលមាន។
2. បាញ់ឲ្យសព្វលើផ្ទៃដែលកខ្វក់ ដោយប្រើសារធាតុសម្លាប់មេរោគដែលផ្សំពីអូសាវែលក្នុងបរិមាណយ៉ាងហោចណាស់មួយភាគធៀបនឹងទឹកដប់ភាគ (1:10)។
3. រើសអង្គធាតុរឹងដែលកខ្វក់ ដោយប្រាកដថាមិនប្រើដៃរបស់អ្នករើសវត្ថុស្រួចដូចជាកញ្ចក់ជាដើមទេ។ ប្រើអំបោស ប្រដាប់ចូកសំរាម ឬឧបករណ៍សម្អាតស្រដៀងៗនេះ ដើម្បីរើសវត្ថុស្រួច។
4. ជូតកន្លែងដែលកខ្វក់ដោយប្រើកន្សែងក្រដាសដែលមានសំណើមផ្ទុកដោយសារធាតុសម្លាប់មេរោគ។
5. ដាក់អង្គធាតុរឹងដែលកខ្វក់ឬសម្ភារសម្អាតទាំងអស់ ទៅក្នុងថង់សារធាតុជីវៈអន្តរាយពណ៌ក្រហមដែលមាននៅក្នុងកញ្ចប់។
6. គួរតែដាក់វត្ថុស្រួចក្នុងតួផ្ទុកការពារធ្លាយសិន មុននឹងដាក់ចូលក្នុងថង់។
7. សម្អាតនិងសម្លាប់មេរោគរបស់របរប្រើប្រាស់ ឬវត្ថុដែលមិនអាចចោលបានផ្សេងទៀត ដែលបានប្រើក្នុងការសម្អាត។
8. ដកឧបករណ៍ការពារផ្ទាល់ខ្លួនចេញ ហើយដាក់វានៅក្នុងថង់សារធាតុជីវៈអន្តរាយពណ៌ក្រហម។
9. រុំនិងចងថង់ក្រហម រួចប្រគល់ថង់សារធាតុជីវៈអន្តរាយនោះ ទៅឲ្យបុគ្គលទទួលបន្ទុក។
10. លាងដៃនិងមុខរបស់អ្នកភ្លាម ដោយប្រើសាប៊ូ។

## បើអ្នកប៉ះផ្ទាល់នឹងភ្នាក់ងារបង្ករោគក្នុងឈាម

1. លាងសម្អាតផ្នែកទាំងអស់នៃរាងកាយរបស់អ្នកដែលបានប៉ះផ្ទាល់ ភ្លាមៗ។
2. ជូនដំណឹងជូរគ្រប់គ្រងអំពីហេតុការណ៍។
3. ស្វែងរកជំនួយនិងការតាមដានផ្នែកវេជ្ជសាស្ត្រ។
4. រៀបចំឯកសារស្តីពីរបាយការណ៍នៃហេតុការណ៍។

# អាកាសធាតុអាក្រក់ខ្លាំង

## ប្រសិនបើមានការព្រមានពីអាកាសធាតុអាក្រក់ខ្លាំង៖

1. តាមដានអាកាសធាតុ។ (មើលនិយមន័យនៃភាពធ្ងន់ធ្ងរខាងក្រោម)
2. ទាក់ទងទៅជូរគ្រប់គ្រង។
3. ពិនិត្យឡើងវិញនូវតំបន់សុវត្ថិភាពនៃអគារ ជាមួយអ្នកចាត់ការនិងបុគ្គលិក។
   តំបន់សុវត្ថិភាពគួរតែនៅជិតជញ្ជាំង ឬសសរទ្រនៅកណ្តាលឬខាងក្រោយនៃអគារ និងឆ្ងាយពីជញ្ជាំងកញ្ចក់ ច្រកចេញចូលកញ្ចក់
   និងបង្អួច។ យកកាបូបសង្គ្រោះបន្ទាន់តាមខ្លួនទៅកាន់ទីតាំងទាំងនោះ។

| | |
|---|---|
| ទីតាំងនៃតំបន់សុវត្ថិភាពទី1៖ | |
| ទីតាំងនៃតំបន់សុវត្ថិភាពទី2៖ | |

## ប្រសិនបើអាកាសធាតុអាក្រក់ខ្លាំងត្រូវបានរកឃើញនៅជិតអគារ៖

1. ធ្វើការប្រកាសនៅក្នុងអាគារចំនួនបីដង។ គំរូ៖ ***"សូមស្តាប់ខ្ញុំដោយយកចិត្តទុកដាក់។ សេវាកម្មអាកាសធាតុជាតិ បានបន្លឺសំឡេងព្រមានអំពីអាកាសធាតុអាក្រក់ខ្លាំង (ព្យុះកំបុតត្បូង) សម្រាប់តំបន់នេះ។ សូមផ្លាស់ទីឲ្យឆ្ងាយពីបង្អួច ហើយផ្លាស់ទីទៅកណ្តាល ឬខាងក្រោយហាង។ សូមនៅទីនោះរហូតទាល់តែ មានការផ្តល់សញ្ញា'សុវត្ថិភាពពេញលេញ'។"***

2. ពិនិត្យគ្រប់តំបន់ទាំងអស់នៃអគារ
   ដើម្បីប្រាកដថាអ្នកគ្រប់គ្នាបានផ្លាស់ទីទៅកាន់តំបន់ជួបជុំដែលបានកំណត់ហើយ។ **ចំណាំ៖ ជូរគ្រប់គ្រង មិនមានអំណាចក្នុងការឃុំឃាំងភ្ញៀវ និងបុគ្គលិកដែលចង់ចាកចេញពីអគារក្នុងអំឡុងនៃអាកាសធាតុអាក្រក់ខ្លាំង ឬព្យុះកំបុតត្បូងនោះទេ។ កុំចាក់សោទ្វារចេញ។**

## ការពារលុយនិងទំនិញ បើធ្វើបែបនេះមិនគំរាមដល់សុវត្ថិភាពរបស់នរណាម្នាក់ទេ៖

1. បិទនិងចាក់សោម៉ាស៊ីនទូទាត់ចេញក្រៅ និងម៉ាស៊ីនគិតលុយទាំងអស់។
2. ចាក់សោប្រអប់សុវត្ថិភាពបន្ទប់ដាក់លុយ/គ្រប់គ្រង និងចាក់សោទ្វារទៅបន្ទប់ដាក់លុយ/គ្រប់គ្រង។
3. បិទម៉ាស៊ីនបូមដោយប្រើកុងតាក់បិទអាសន្ន។

បើមានការខូចខាតទ្រព្យសម្បត្តិដោយសារអាកាសធាតុអាក្រក់ខ្លាំង៖

1. កុំធ្វើឲ្យភ្ញៀវឬបុគ្គលិកណាមួយមានគ្រោះថ្នាក់។ ជម្លៀសចេញពីអគារបើមានគ្រោះថ្នាក់ដែលអាចកើតឡើង (ឧទាហរណ៍៖ លេចធ្លាយឧស្ម័ន ខ្សែភ្លើងធ្លាក់ ខូចខាតរចនាសម្ព័ន្ធ ជាដើម)។ មើលផែនការជម្លៀសនៅខាងលើ។
2. ត្រួតពិនិត្យការខូចខាត បើអាចធ្វើបានដោយមានសុវត្ថិភាព។ ហៅទូរស័ព្ទទៅអ្នកត្រួតពិនិត្យអគារ ឬក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក ដើម្បីទទួលជំនួយលើបញ្ហានេះ។ កត់បញ្ជី៖
   a. ការខូចខាតជំបូល
   b. ការខូចខាតរចនាសម្ព័ន្ធ
   c. ការបាត់បង់ទំនិញ/ផលិតផល
3. ហៅទូរសព្ទទៅមធ្យោបាយទាក់ទងអាសន្នបុគ្គលិក បើចាំបាច់។

## ប្រសិនបើជំបូលលេចធ្លាយ៖

- គ្របផលិតផល ទំនិញ និងឧបករណ៍ ដោយប្រើប្លាស្ទិច។
- ដាក់ធុងសំរាមទទេ នៅក្រោមកន្លែងលេចធ្លាយ។
- លើកទំនិញឲ្យផុតពីកម្រាលឥដ្ឋ យ៉ាងទាបបំផុតត្រឹមក្តារក្រាលអីវ៉ាន់។
- ចងខ្សែបិទឃាំងកន្លែងដែលខូចខាត។

## ប្រសិនបើមានទឹកនៅក្នុងអគារ៖

ត្រូវប្រាកដថាមិនមានគ្រោះថ្នាក់អន្តរាយផ្នែកអគ្គិសនីទេ ហើយមិនកខ្វក់ដល់អាហារទេ។
រុញទឹកចេញពីអាគារដោយប្រើប្រដាប់រុញទឹក អំបោស ប្រដាប់ជូតឥដ្ឋ ឬច្រាស។

## រៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់៖

ត្រូវប្រាកដថាបុគ្គលទទួលបន្ទុកទីតាំង បានកត់ត្រា និងរៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់ដែលកើតឡើងជាលទ្ធផលនៃស្ថានភាពអាសន្ន។

## និយមន័យនៃភាពធ្ងន់ធ្ងររបស់អាកាសធាតុ៖

| | |
|---|---|
| **ឃ្លាំមើលព្យុះរដូវរងា៖**<br>អាចនឹងមានអាកាសធាតុរដូវរងាដ៏ខ្លាំងក្លានិងអន្តរាយ<br>ក្នុងរយៈពេល 48 ម៉ោង។ | **ឃ្លាំមើលព្យុះកំបុតត្បូង៖**<br>មានលទ្ធភាពកើតមានព្យុះផ្គររន្ទះ និងព្យុះកំបុតត្បូង នៅក្នុងនិងនៅជិតតំបន់ឃ្លាំ<br>មើល។ |
| **ព្រមានពីព្យុះរដូវរងា៖**<br>ព្រិលធ្លាក់ខ្លាំងចាប់ពី6អ៊ីញឡើងទៅក្នុងរយៈពេល12ម៉ោង ចាប់ពី8អ៊ីញឡើងទៅក្នុងរយៈពេល24ម៉ោង ឬ ចាប់ពីមួយភាគពីរអ៊ីញឡើងទៅនៃគំនរព្រិល<br>ត្រូវបានរំពឹងទុក។ | **ព្រមានពីព្យុះកំបុតត្បូង៖** ព្យុះកំបុតត្បូងជិតមកដល់ ឬកំពុងកើតឡើង។ ចូលជម្រកភ្លាម។ |
| **ព្រមានពីភាពត្រជាក់ខ្លាំង៖** ខ្យល់បក់ជាប់ ត្រូវបានរំពឹងថានឹងបង្កើតសន្ទស្សន៍ញ័ររងាខ្យល់ ចាប់ពី -20°F ឡើងទៅ ឬ ចាប់ពី -25°F ឡើងទៅ (អាស្រ័យលើទីតាំង) យ៉ាងហោចណាស់ 3 ម៉ោង។ | **យោបល់ពីកម្តៅ៖** សន្ទស្សន៍កម្តៅពេលថ្ងៃចាប់ពី 95°F ដល់ 99°F ក្នុងរយៈពេលចាប់ពី 2 ម៉ោងឡើងទៅ ក្នុងរយៈពេល 2 ថ្ងៃជាប់ៗគ្នា ឬ ចាប់ពី100°F ដល់ 104°F ក្នុងរយៈពេលចាប់ពី 2 ម៉ោងឡើងទៅ ក្នុងមួយថ្ងៃ ត្រូវបានរំពឹងទុក។ |
| **ព្រមានពីព្យុះព្រិល៖** ខ្យល់បក់ជាប់ ឬខ្យល់បោកបក់ញឹកញាប់ ចាប់ពី 35 ម៉ាយក្នុងមួយម៉ោងឡើងទៅ រួមជាមួយនឹងការធ្លាក់ និង/ឬការបោកបក់ព្រិលខ្លាំងគួរឲ្យកត់សម្គាល់ ត្រូវបានរំពឹងថានឹងកាត់បន្ថយការមើលឃើញឲ្យនៅតិចជាងមួយភាគបួនម៉ាយ ក្នុងរយៈពេលចាប់ពី 3 ម៉ោងឡើងទៅ។ លក្ខខណ្ឌរបស់ព្យុះព្រិល ត្រូវតែជាលក្ខខណ្ឌអាកាសធាតុដែលត្រូវតាមដានបំផុត | **ព្រមានពីទឹកជំនន់តាមឆ្នេរ៖**<br>ទឹកជំនន់តាមឆ្នេរកម្រិតមធ្យមឬធំ<br>ត្រូវបានរំពឹងថានឹងធ្វើឲ្យខូចខាតទ្រព្យសម្បត្តិ<br>និង/ឬគំរាមដល់អាយុជីវិត។ |

| | |
|---|---|
| ក្នុងអំឡុងពេលនេះ។ | |
| **ព្រមានពីទឹកជំនន់គំហុក៖**លំហូរយ៉ាងលឿននិងខ្លាំងនៃទឹកធំ ចូលទៅក្នុងតំបន់ដែលជាធម្មតាមានសភាពស្ងួត ឬការកើនឡើងភ្លាមៗនៃកម្រិតទឹកនៅក្នុងអូរឬព្រែកលើសកម្រិតទឹកជំនន់ដែលបានកំណត់ទុកជាមុន ត្រូវបានរំពឹងទុក ឬកំពុងកើតឡើង។ | **ព្រមានពីព្យុះរលក៖**<br>ការជោរជន់ដែលគំរាមកំហែងដល់អាយុជីវិត ដោយសារការកើនឡើងនៃទឹកដែលផ្លាស់ទីពីច្រាំងទៅដីគោក ត្រូវបានរំពឹងទុកនៅក្នុងតំបន់ដែលបានបញ្ជាក់ ជាទូទៅក្នុងរយៈពេល 36 ម៉ោង។ |
| **ឃ្លាំមើលព្យុះត្រូពិច៖**<br>ព្យុះស៊ីក្លូនត្រូពិចដែលមានកម្លាំងខ្យល់ពី 34 ទៅ 63kt (39 ទៅ 73 ម៉ាយក្នុងមួយម៉ោង) ឬខ្លាំងជាងនេះ បង្កការគំរាមកំហែងដែលអាចកើតមាន ជាទូទៅក្នុងរយៈពេល 48 ម៉ោង។<br>ខ្យល់បែបនេះអាចត្រូវបានអមដោយព្យុះរលក ទឹកជំនន់តាមឆ្នេរ និង/ឬទឹកជំនន់ទន្លេ។ | **ព្រមានពីព្យុះត្រូពិច៖** ការព្រមានពីព្យុះត្រូពិច ត្រូវបានដាក់ចេញនៅពេលដែលខ្យល់បក់ជាប់ពី 34 ទៅ 63kt (39 ទៅ 73 ម៉ាយក្នុងមួយម៉ោង) ឬខ្លាំងជាងនេះ ដែលមានទាក់ទងនឹងព្យុះស៊ីក្លូនត្រូពិច ត្រូវបានរំពឹងថានឹងមានក្នុងរយៈពេល 36 ម៉ោង ឬតិចជាងនេះ។<br>ខ្យល់បែបនេះអាចត្រូវបានអមដោយព្យុះរលក ទឹកជំនន់តាមឆ្នេរ និង/ឬទឹកជំនន់ទន្លេ។ |
| **ឃ្លាំមើលព្យុះសង្ឃរា៖**<br>ត្រូវបានដាក់ចេញនៅពេលដែលព្យុះស៊ីក្លូនត្រូពិចដែលមានកម្លាំងខ្យល់បក់ជាប់ 74 ម៉ាយក្នុងមួយម៉ោង (64 kt) ឬខ្លាំងជាងនេះ បង្កការគំរាមដែលអាចកើតមានដល់តំបន់ឆ្នេរ ឬតំបន់ដីគោក ជាទូទៅក្នុងរយៈពេល 48 ម៉ោង។ ខ្យល់បែបនេះអាចត្រូវបានអមដោយព្យុះរលក ទឹកជំនន់តាមឆ្នេរ និង/ឬទឹកជំនន់ទន្លេ។ ការឃ្លាំមើលបង្ហាញពីការអាចកើតមានលក្ខខណ្ឌព្យុះសង្ឃរា ប៉ុន្តែមិនធានាថាវានឹងកើតឡើងនោះទេ។ | **ព្រមានពីព្យុះសង្ឃរា៖** កម្លាំងខ្យល់បក់ជាប់ក្នុងល្បឿន 74 ម៉ាយក្នុងមួយម៉ោង (64 kt) ឬខ្លាំងជាងនេះ ដែលមានជាប់ទាក់ទងនឹងព្យុះសង្ឃរា ត្រូវបានរំពឹងថានឹងប៉ះពាល់ដល់តំបន់ឆ្នេរ ឬតំបន់ដីគោក ក្នុងរយៈពេល 36 ម៉ោង។ |

# អគ្គិភ័យ

បើមានគេរាយការណ៍ពីអគ្គិភ័យ **ត្រូវទាញកណ្ដឹងរោទ៍អគ្គិភ័យ** (បើមាន ហើយមិនទាន់ត្រូវបានដាក់ឲ្យដំណើរការ) ដើម្បីព្រមានឲ្យអ្នកនៅក្នុងអគារជម្លៀសចេញ។ បន្ទាប់មក **តេទៅលេខ911** ដើម្បីប្រកាសប្រាប់នាយកដ្ឋានពន្លត់អគ្គិភ័យ។ **ផ្ដល់ព័ត៌មានខាងក្រោមនេះ៖**

- ឈ្មោះអាជីវកម្ម និងអាសយដ្ឋានផ្លូវ
- លក្ខណៈរបស់អគ្គិភ័យ (ឧទាហរណ៍៖ ឧបករណ៍អគ្គិសនី ខ្លាញ់ ក្រដាស សារធាតុគីមី)
- ទីតាំងរបស់អគ្គិភ័យ (អគារ និង ជាន់)
- ប្រភេទរបស់កណ្ដឹងរោទ៍អគ្គិភ័យ (ឧទាហរណ៍៖ ចាប់សញ្ញា ប្រអប់ទាញចុះ ក្បាលបាញ់ស្រោចទឹកហូរ)
- ទីតាំងរបស់កណ្ដឹងរោទ៍អគ្គិភ័យ (ឧទាហរណ៍៖ អគារ និង ជាន់)
- ឈ្មោះនិងលេខរបស់អ្នករាយការណ៍ពីអគ្គិភ័យ

## នីតិវិធី

1. **ជម្លៀស៖** ជម្លៀសអ្នកនៅក្នុងអគារតាមផ្លូវជម្លៀស ទៅកាន់តំបន់ជួបជុំបឋមដែលនៅខាងក្រៅ។
2. **បង្វែរទិស៖** បង្វែរទិសអ្នកនៅក្នុងអគារទៅកាន់ជណ្ដើរជើង និងឲ្យចេញឆ្ងាយពីភ្លើង។
3. **ហាមឃាត់៖** ហាមប្រើជណ្ដើរយន្តប្រអប់។
4. **កត់បញ្ជីបុគ្គលិកទាំងអស់៖** កត់បញ្ជីបុគ្គលិក និងភ្ញៀវទាំងអស់នៅតំបន់ជួបជុំ។
5. **ជួបជាមួយនាយកដ្ឋានពន្លត់អគ្គីភ័យ៖** ប្រាប់ទៅនាយកដ្ឋានពន្លត់អគ្គីភ័យ ប្រសិនបើគ្រប់គ្នាត្រូវបានកត់បញ្ជីរួចហើយ និងប្រសិនបើមានអ្នករបួស។ ធ្វើបច្ចុប្បន្នភាពពីលក្ខណៈរបស់ស្ថានភាពអាសន្ន និងសកម្មភាពដែលបានធ្វើ។ ផ្ដល់ប្លង់ជាន់អគារ កូនសោ និងជំនួយផ្សេងទៀត ទៅតាមការស្នើសុំ។

## ចំណាំ៖

- អគ្គីភ័យនិងស្ថានភាពអាសន្នទាំងអស់ នឹងត្រូវបានរាយការណ៍ឆាប់បំផុតតាមដែលអាចធ្វើបាន ដោយមធ្យោបាយមួយក្នុងចំណោមមធ្យោបាយខាងក្រោម៖
    - ដោយផ្ទាល់មាត់ ឲ្យបានឆាប់បំភុតតាមដែលអាចធ្វើទៅបាន ក្នុងអំឡុងនៃម៉ោងធ្វើការធម្មតា ឬ
    - តាមទូរស័ព្ទ នៅក្រៅម៉ោងធ្វើការធម្មតា ឬនៅថ្ងៃចុងសប្ដាហ៍

- គ្មានកាលៈទេសៈណាដែលបុគ្គលិកគួរព្យាយាមពន្លត់ភ្លើង ក្រោយពីមិនអាចពន្លត់បានដោយប្រើបំពង់ពន្លត់អគ្គិភ័យទេ ហើយក៏គ្មានបុគ្គលិកណាម្នាក់ដែលគួរព្យាយាមចូលទៅក្នុងអគារដែលកំពុងឆេះ ដើម្បីធ្វើការស្វែងរក និងជួយសង្គ្រោះដែរ។

## ទីតាំងរបស់បំពង់ពន្លត់អគ្គិភ័យ

| ទីតាំង |
|---|
| |
| |

## ប្រព័ន្ធការពារអគ្គិភ័យ

រៀបចំឯកសារអំពីប្រព័ន្ធការពារអគ្គិភ័យ ដោយមានរួមបញ្ចូលទាំងប្រភេទរបស់ប្រព័ន្ធ ទីតាំង តំបន់ ឬគ្រោះថ្នាក់អន្តរាយដែលត្រូវបានការពារ និងជំបូន្មាន។ បើអ្នកមិនប្រាកដទេ ត្រូវទាក់ទងទៅម្ចាស់ដី ឬម្ចាស់អគារ។

| ប្រភេទរបស់ប្រព័ន្ធ | ទីតាំង | ចំណុចចូលបាន / ជំបូន្មាន |
|---|---|---|
| ប្រព័ន្ធក្បាលបាញ់ស្រោច | សន្ទះបញ្ជា | |
| | សន្ទះបញ្ជា | |
| | សន្ទះបញ្ជា | |
| ម៉ាស៊ីនបូមទឹកពន្លត់អគ្គិភ័យ | | |
| ប្រព័ន្ធពន្លត់អគ្គិភ័យពិសេស | | |
| | | |
| | | |

បញ្ចូលផែនទីរបស់ឧបករណ៍ប្រើប្រាស់និងប្រព័ន្ធការពារអគ្គិភ័យ

# អំពើហិង្សានៅកន្លែងការងារ

## ប្រសិនបើមានកើតឡើងនូវការវាយប្រហារហិង្សា ឬការបាញ់ប្រហារ

- **ហៅទូរស័ព្ទទៅលេខ911។**
- **រត់ ពួន ឬ ប្រយុទ្ធ**។ បើអាចធ្វើបានដោយសុវត្ថិភាព ត្រូវជម្លៀសចេញពីតំបន់នោះ។ កុំធ្វើអ្វីដែលនាំឲ្យមានហានិភ័យដល់សុវត្ថិភាពរបស់អ្នក ឬសុវត្ថិភាពរបស់អ្នកដទៃ។
- ចំណាំដោយប្រុងប្រយ័ត្ននូវការលក្ខណៈរូបរាងរបស់ជនល្មើស រួមទាំងលក្ខណៈសម្គាល់ពិសេសរបស់អ្នកវាយប្រហារ។
- **ទាក់ទងនៅពេលមានសុវត្ថិភាព៖**
    - ផ្ញើសារជាអក្សរ ឬប្រើមធ្យោបាយទាក់ទងស្ងាត់ៗផ្សេងទៀត ដើម្បីផ្តល់ព័ត៌មានដល់អាជ្ញាធរ។
    - បើជាប់ ឬ មិនអាចចាកចេញពីទីតាំងដែលមានសុវត្ថិភាពបាន ត្រូវបញ្ជូនទីតាំងរបស់អ្នកទៅឲ្យអ្នកឆ្លើយតបបឋម។
- **ធ្វើតាមដំបូន្មានរបស់សមត្ថកិច្ច៖** នៅពេលសមត្ថកិច្ចមកដល់ ត្រូវធ្វើតាមការណែនាំរបស់ពួកគាត់ឲ្យបានត្រឹមត្រូវ។
    - ដាក់ដៃនៅកន្លែងដែលគេមើលឃើញ និងជៀសវាងធ្វើចលនាលឿនភ្លាមៗ។

## បើមានការប្រកាសពីការបិទខ្ទប់៖

មើលផែនការសកម្មភាពអាសន្ន។

## ក្រោយព្រឹត្តិការណ៍

- រង់ចាំសញ្ញាសុវត្ថិភាពពេញលេញពីសមត្ថកិច្ច ឬមន្ត្រីអាសន្នជាមុនសិន មុននឹងចាកចេញពីតំបន់ជម្រក។
- ពិនិត្យមើលភាពសុខសប្បាយរបស់បុគ្គលិក និងអតិថិជនទាំងអស់។ ធ្វើការសង្គ្រោះបឋមទៅតាមការចាំបាច់។

- សម្របសម្រួលជាមួយអាជ្ញាធរក្នុងអំឡុងពេលស៊ើបអង្កេត និងធានាឲ្យមានការតាមដានដែលសមស្រប ដូចជាប្រឹក្សា ឬគាំទ្រដល់បុគ្គលដែលរងផលប៉ះពាល់។

# ការលួចប្លន់

បើអ្នកឃើញឧក្រិដ្ឋកម្ម ត្រូវផ្លាស់ទីទៅទីតាំងដែលមានសុវត្ថិភាព។ បើអាច ត្រូវជួយអ្នកដែលមានតម្រូវការចូលឬតម្រូវការមុខងារ ទៅកាន់ទីតាំងដែលមានសុវត្ថិភាពផង។

## នៅពេលដែលចោរទៅបាត់៖

1. កុំព្យាយាមតាមចោរ។
2. សរសេរពីលក្ខណៈរបស់ចោរ រថយន្តជិះរត់ និងស្លាកលេខ។
3. **ហៅទូរស័ព្ទទៅលេខ911។**
4. ហៅទូរស័ព្ទទៅមធ្យោបាយទាក់ទងអាសន្នរបស់អ្នក។
5. រៀបចំឯកសារអំពីហេតុការណ៍ និងបំពេញរបាយការណ៍ប៉ូលីស។

## កុំរំខានដល់កន្លែងកើតហេតុ៖

ត្រូវប្រាកដថាតំបន់នោះត្រូវបានធានា ដើម្បីទប់ស្កាត់មិនឲ្យនរណាម្នាក់ចូលទៅក្នុងកន្លែងកើតហេតុឬតំបន់ជុំវិញនោះ។

# កង្វក់ផលិតផល

## ប៉ាន់ប្រមាណស្ថានការណ៍៖

- កំណត់...
  - វិសាលភាពនៃកង្វក់
  - តម្រូវការចូលរួមពីភ្នាក់ងារសាធារណៈ។
- បើមានការសង្ស័យថាមានការផ្ទុះឡើងនៃជំងឺពីចំណីអាហារ ត្រូវបញ្ឈប់ជាបន្ទាន់នូវការលក់អាហារដែលអាចរងកង្វក់ ហើយហៅទូរស័ព្ទទៅលេខ911 ឬជូនដំណឹងទៅគណៈកម្មការសុខភាពសាធារណៈភ្លាមៗ។
- បើមានការសង្ស័យថាមានការបន្លំផលិតផលដោយចេតនា ត្រូវទាក់ទងទៅសមត្ថកិច្ច

និងការពារអ្វីដែលអាចនឹងក្លាយជាភស្តុតាង។

## ចាត់វិធានការដើម្បីរឹតត្បិតការប៉ះផ្ទាល់៖

- ទាញយកផលិតផលចេញ ប្រសិនបើសមស្រប។
- កំណត់...
  - ថានឹងត្រូវមានការប្រកាសជាសាធារណៈឬទេ
  - ថាត្រូវការហៅប្រមូលផលិតផលមកវិញឬទេ

## រៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់៖

ត្រូវប្រាកដថាបានកត់ត្រា និងរៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់ដែលកើតឡើងជាលទ្ធផលនៃស្ថានភាពអាសន្ន។

# ទឹកជំនន់

## ប្រសិនបើមានការគំរាមពីទឹកជំនន់៖

1. តាមដានអាកាសធាតុ។
2. ទាក់ទងទៅមធ្យោបាយទាក់ទងអាសន្នបុគ្គលិក ប្រសិនបើចាំបាច់។
3. រៀបចំលើកទំនិញ វត្ថុមានតម្លៃ ឧបករណ៍ម៉ាស៊ីន និងគ្រឿងអេឡិចត្រូនិច យ៉ាងទាបបំផុត 12 អ៊ីញ ពីកម្រាលឥដ្ឋ (ប្រើក្តារក្រាលអីវ៉ាន់ជាជម្រើសល្អ)។
4. ដឹងពីរបៀបផ្តាច់របស់របរប្រើប្រាស់។

**<u>ឃ្លាំមើលទឹកជំនន់៖</u>** មានលទ្ធភាពកើតមានទឹកជំនន់។ ចូលស្តាប់វិទ្យុ NOAA។ ត្រៀមខ្លួនដើម្បីជម្លៀស។ ចូលស្តាប់វិទ្យុ និងមើលទូរទស្សន៍ក្នុងមូលដ្ឋាន ដើម្បីទទួលបានព័ត៌មានបន្ថែម។

**<u>ព្រមានពីទឹកជំនន់៖</u>** កំពុងមានទឹកជំនន់រួចហើយ ឬនឹងមានទឹកជំនន់ក្នុងពេលឆាប់ៗ។ ធ្វើការប្រុងប្រយ័ត្នភ្លាមៗ។ ត្រៀមខ្លួនទៅកាន់ទីខ្ពស់។ បើមានការណែនាំ ត្រូវជម្លៀសចេញភ្លាមៗ។

## ប្រសិនបើឃើញទឹកជំនន់នៅជិតហាង៖

1. ចាប់ផ្តើមដំណើការបាវខ្សាច់។
2. ពិនិត្យឡើងវិញនូវនីតិវិធីកង្វក់ទឹក។
3. ត្រូវប្រាកដថាទំនិញ វត្ថុមានតម្លៃ ឧបករណ៍ម៉ាស៊ីនទាំងអស់ ត្រូវបានលើកឡើង។

4. បិទថាមពលអគ្គិសនីនៅប្រអប់កុងតាក់មេ។ នៅពេលដែលត្រៀមហាងដើម្បីជម្លៀសរួចរាល់ហើយ ត្រូវផ្ដាច់ម៉ាស៊ីនភ្លើងអាសន្ន (ប្រសិនបើមាន)។ ត្រូវប្រាកដថាគ្រឿងបរិក្ខារ ត្រូវបានដកឌុយចេញ ដើម្បីជៀសវាងការឆេះនៅពេលភ្លើងត្រឡប់មកវិញ។
5. ផានារបស់របរប្រើប្រាស់ ឧបករណ៍ ស្រោមក្រណាត់ កញ្ចប់វេចខ្ចប់ និងវត្ថុប្រើម្ដងចោល មិនឲ្យប៉ះផ្ទាល់/ វេងកង្វក់ នៅក្នុងអំឡុងនៃទឹកជំនន់។

## ជម្លៀសចេញពីហាង ប្រសិនបើសុវត្ថិភាពរបស់ភ្ញៀវនិងបុគ្គលិករងការគំរាម និង/ឬ ប្រសិនបើអ្នកត្រូវបានបញ្ជាឲ្យជម្លៀស៖

មើលផែនការជម្លៀស នៅខាងលើ។

## ការពារលុយនិងទំនិញ បើធ្វើបែបនេះមិនគំរាមដល់សុវត្ថិភាពរបស់នរណាម្នាក់ទេ៖

1. បិទនិងចាក់សោម៉ាស៊ីនទូទាត់ចេញក្រៅ និងម៉ាស៊ីនគិតលុយទាំងអស់។
2. ចាក់សោប្រអប់សុវត្ថិភាពបន្ទប់ដាក់លុយ/គ្រប់គ្រង និងចាក់សោទ្វារទៅបន្ទប់ដាក់លុយ/គ្រប់គ្រង។

## ក្រោយពីទឹកជំនន់ស្រកទៅវិញហើយ៖

1. រៀបចំឯកសារអំពីការខូចខាតណាមួយ ហើយហៅទូរសព្ទទៅអ្នកផ្ដល់សេវាធានារ៉ាប់រងរបស់អ្នកដើម្បី រាយការណ៍។
2. ចូលហាងដោយប្រុងប្រយ័ត្ន។ ត្រូវប្រាកដថាមន្ត្រីដែលសមស្រប ចូលកន្លែងដោយប្រុងប្រយ័ត្ន។
3. ម្ចាស់កន្លែង/អ្នកថែទាំ នឹងពិនិត្យសេវាអគ្គិសនី មុនពេលបើកភ្លើង។
4. ទាក់ទងទៅនាយកដ្ឋានអគារក្នុងតំបន់ និងភ្នាក់ងារសមស្របផ្សេងទៀត ដើម្បីកំណត់ថាតើរចនាសម្ព័ន្ធអគារមានសុវត្ថិភាព និងត្រូវបានអនុញ្ញាតឲ្យចូលឬទេ។
5. ធ្វើការសម្អាតទូទៅ ដោយធានាសុខភាព និងសុវត្ថិភាពរបស់អ្នកធ្វើការ។ សម្អាត និងរក្សាអនាម័យឧបករណ៍និងរបស់របរប្រើប្រាស់។
6. ញែកអាហារ ឧបករណ៍ របស់របរប្រើប្រាស់ ស្រោមក្រណាត់ និងវត្ថុប្រើម្ដងចោល ដែលស្រោចស្រង់បានចេញពីរបស់ដែលស្រោចស្រង់មិនបាន ឲ្យបានលឿនតាមដែលអាចធ្វើទៅបាន។
7. បោះចោលរបស់របរដែលមិនអាចស្រោចស្រង់បាន ឲ្យបានត្រឹមត្រូវ។

## ការណែនាំពីការសម្អាត៖

- អាហារ ឧបករណ៍ របស់របរប្រើប្រាស់ ស្រោមក្រណាត់ និងវត្ថុប្រើម្តងចោល ដែលខូចទាំងអស់ ត្រូវតែកម្ទេចនិងបោះចោលឲ្យបានត្រឹមត្រូវ។
- កម្រាលឥដ្ឋ ជញ្ជាំង គ្រឿងសង្ហារិម កម្រាលព្រំ របស់របរប្រើប្រាស់ និងឧបករណ៍ ដែលខូចខាតមិនអាចស្រោចស្រង់បាន ត្រូវតែយកចេញ និងជំនួសទៅតាមការចាំបាច់។
- ជញ្ជាំង កម្រាលឥដ្ឋ និងផ្ទៃឧបករណ៍ ដែលរងផលប៉ះពាល់ ត្រូវតែសម្អាតដោយសាប៊ូនិងទឹក លាងជម្រះ និងរក្សាអនាម័យ។ កម្រាលព្រំ គួរតែត្រូវបានយកចេញ ឬសម្អាតដោយចំហាយទឹក។
- យកសម្ភារសើមចេញ។ បោះចោលសម្ភារទាំងឡាយណាដែលមិនអាចសម្អាត និងរក្សាអនាម័យបានដោយមានប្រសិទ្ធភាព។
- ដកទឹកដែលដក់ចេញ។
- សម្អាត និងរក្សាអនាម័យរបស់របរប្រើប្រាស់ និងឧបករណ៍នានានៅក្នុងតំបន់ដែលរងផលប៉ះពាល់។
- ប្រើសូលុយស្យុងសាប៊ូដើម្បីសម្អាតកម្រាលឥដ្ឋ ឧបករណ៍ និងតំបន់ដែលរងផលប៉ះពាល់ផ្សេងទៀត បន្ទាប់មកលាងជម្រះដោយទឹកស្អាត។
- រក្សាអនាម័យលើកម្រាលឥដ្ឋ និងតំបន់ដែលរងផលប៉ះពាល់ផ្សេងទៀត ដោយប្រើសូលុយស្យុងរក្សាអនាម័យទឹកថ្លា (អូសាវែល 8 oz ក្នុង 5 gallon នៃទឹក = សូលុយស្យុងក្លរីន 500ភាគលាន )។
- សម្ងួតដោយខ្យល់លើតំបន់ដែលរងផលប៉ះពាល់។
- បោកគក់ ឬចោលក្បាលជូត និងរបស់ជំនួយការសម្អាតផ្សេងទៀតដែលប៉ះនឹងទឹកជន់លិច។
- វិធានការផ្សេងដែលអាចជំនួសគ្នាបាន៖ ជួលសេវាកម្មអនាម័យដែលមានជំនាញក្នុងការសម្អាតកន្លែងអាហារដែលប៉ះផ្ទាល់នឹងទឹកជំនន់។
- អាហារ ស្រោមក្រណាត់ វត្ថុប្រើម្តងចោល ដែលរងកង្វក់
- ចោលរបស់របរអាហារ ( ខ្ចប់ ឬមិនខ្ចប់) ដែលប៉ះនឹងទឹកជន់លិច។
- បោកគក់ស្រោមក្រណាត់ ឬឯកសណ្ឋានណាដែលប៉ះនឹងទឹកជន់លិច។
    - បោកគក់ដាច់ដោយឡែកពីស្រោមក្រណាត់ផ្សេងទៀត។
    - ប្រើអូសាវែល។
    - ប្រើម៉ាស៊ីនសម្ងួតម៉េកានិច។
    - ចោលវត្ថុប្រើម្តងចោលដែលប៉ះនឹងទឹកជន់លិច។

## រៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់៖

ត្រូវប្រាកដថាបានកត់ត្រា
និងរៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់ដែលកើតឡើងជាលទ្ធផលនៃស្ថានភាពអាសន្ន។

យោងលើ **Ready.gov Business - *FLASH Inland Flooding Toolkit* ដើម្បីទទួលបានព័ត៌មានបន្ថែម។**

---

## ការប៉ាន់ប្រមាណទូទៅពីភាពស្រោចស្រង់បាននៃទឹកជំនន់៖

ទឹកជន់លិច អាចមានផ្ទុកដីល្បាប់ ទឹកលូស្អុយ ប្រេង ឬកាកសំណល់គីមី
ដែលអាចធ្វើឲ្យអាហារដែលខូចដោយសារព្យុះ មិនមានសុវត្ថិភាពក្នុងការបរិភោគ
ប្រសិនបើកញ្ចប់វេចខ្ចប់របស់វារងកង្វក់។ ចោលអាហារ ឬសម្ភារៈវេចខ្ចប់អាហារណាដែលប៉ះនឹងទឹកជន់លិច។
មានអាហារ ឬភេសជ្ជៈតិចតួចណាស់ដែលអាចស្រោចស្រង់បានក្រោយពីប៉ះផ្ទាល់នឹងទឹកជន់លិច។
អាហារនៅក្នុងកញ្ចប់វេចខ្ចប់ទន់ ឬមានគម្របមួល ត្រូវតែត្រូវកម្ទេចចោល។ ក្នុងករណីខ្លះ
ទំនិញកំប៉ុងនៅក្នុងកំប៉ុងដែកឬតួផ្ទុកប្លាស្ទិចរឹង អាចស្រោចស្រង់បាន។ ទោះបីជាបែបនេះក៏ដោយ
លក្ខខណ្ឌរបស់កំប៉ុងគឺជាកត្តាកំណត់មួយទៀត។ វត្តមាននៃច្រែះ ដី ឬការខូចខាតស្លាកសញ្ញា
ជាឧបសគ្គនៃការស្រោចស្រង់។

ទឹកជន់លិច អាចធ្វើឲ្យអាហារមិនមានសុវត្ថិភាពក្នុងការបរិភោគ ជាពិសេសប្រសិនបើកញ្ចប់វេចខ្ចប់រងកង្វក់។
**ចោល**អាហារខាងក្រោមនេះ ប្រសិនបើទឹកបានគ្របដណ្ដប់ សាចលើ ស្រក់លើ ឬជ្រាបចូលក្នុងកញ្ចប់វេចខ្ចប់៖

- ភេសជ្ជៈមានជាតិអាល់កុល៖ មើល RIDOH សម្រាប់ការណែនាំលម្អិត។ ក្នុងករណីខ្លះ កំប៉ុងឬដបទទេ "ដែលអាចយកមកវិញបាន" អាចត្រូវបានស្រោចស្រង់ដើម្បីទទួលបានតម្លៃជាប្រាក់។
- អាហារ អាហាររំលែក ផលិតផលស្រស់ សាច់ បសុបក្សី ត្រី និងស៊ុត ដែលបានប៉ះផ្ទាល់។
- អាហារណាដែលវេចខ្ចប់ក្នុងក្រដាស ប្លាស្ទិច ក្រណាត់ ឬសរសៃអំបោះ។
- គេសក្រដាសកាតុង ទោះបីជាមើលទៅអីវ៉ាន់ហាក់បីដូចជាស្ងួតក៏ដោយ ដូចជាគ្រាប់ធញ្ញជាតិ ផលិតផលប៉ាស្តា អង្ករ អំបិល។
- អាហារដែលមានបិទភ្ជាប់ក្រដាសកាតុង ដូចជាម៉ាយ៉ូណេសនិងអន្លក់បន្លែ ឬ មានកញ្ចប់វេចខ្ចប់ដោយក្រដាសបិទឬថង់ប្លាស្ទិច។
- អាហារនៅក្នុងក្រឡកែវ រួមទាំងក្រឡដែលមិនទាន់បានបើកនិងមានក្រដាសក្រមួន ក្រដាសបិទ ថង់ប្លាស្ទិច ឬគម្របក្រណាត់។

- អាហារ របស់រាវ ឬភេសជ្ជៈ នៅក្នុងដបដែលមានគម្របក្ងកា ឬ តួផ្ទុកដែលមានគម្របគាស់បើកទាំងស្រុង ឆ្នុក ឬគម្របវីស្គ័។
- តួផ្ទុកនិងកញ្ចប់វេចខ្ចប់ដែលបានបើកទាំងអស់ និង អាហារនៅក្នុងថង់ឬកំប៉ុង។
- កំប៉ុងដែលប្រឡាក់ លេចធ្លាយ ប៉ោង ឬច្រែះ។
- កំប៉ុងដែលក្រឡាប់ផ្កាប់ផ្ងារ ហើយនៅឆ្ងាយពីកន្លែងស្តុកធម្មតារបស់វា (អាចមានធ្លុះរន្ធ ឬប្រេះថ្នេរ)។
- កំប៉ុងអាចនឹងលក់មិនបាន បើគ្មានព័ត៌មានស្លាកសញ្ញាដែលគេត្រូវការទាំងអស់ទេ។ ដូច្នេះកំប៉ុងដែលមានស្លាកសញ្ញាខូច គួរតែចោល។

## ទំនិញដែលបានស្រោចស្រង់ – ការកែប្រែឡើងវិញ

ទាក់ទងទៅអាជ្ញាធរបទប្បញ្ញត្តិរដ្ឋ សម្រាប់ការណែនាំបន្ថែម។

## ការប៉ាន់ប្រមាណទូទៅពីភាពស្រោចស្រង់បាននៃទឹកជំនន់៖

- យកចេញទៅតំបន់រក្សាអាហារបំបរបង់ដែលបានកំណត់ ឲ្យឆ្ងាយពីកន្លែងរៀបចំអាហារនិងកន្លែងរក្សាឧបករណ៍ ហើយធានាទុកនៅក្នុងតួផ្ទុកសំណល់ដែលបិទគម្រប ឬតំបន់ដាច់ឆ្ងាយផ្សេងទៀត ដើម្បីការពារ សេវាសាធារណៈ ឬទប់ស្កាត់កង្វក់ដោយចៃដន្យលើកន្លែងប្រើប្រាស់ និងអាហារផ្សេងទៀត។
- បើអាហារត្រូវតែរក្សាទុករហូតទាល់តែអ្នកចែកចាយអាចផ្តល់ឥណទានដល់កន្លែង នោះត្រូវតែដាក់ស្លាកសញ្ញាយ៉ាងច្បាស់ថា "មិនមែនសម្រាប់លក់" ហើយរក្សាទុកក្នុងទីតាំងក្លាសេដាច់ដោយឡែកពីអាហារផ្សេងទៀត ហើយទុកសម្រាប់ឥណទាន។
- អាហារក្លាសេដែលបានចោល អាចត្រូវបានកត់ត្រាដោយអ្នកផ្គត់ផ្គង់/អ្នកចែកចាយអាហារ។
- កន្លែងគួររៀបចំឯកសារអំពីប្រភេទនិងបរិមាណអាហារ ថ្លៃចំណាយ និងហេតុផលសម្រាប់ការបោះចោល សម្រាប់គោលបំណងធានារ៉ាប់រង និងបទប្បញ្ញត្តិ។
- មួយភាគតូចនៃអាហារដែលត្រូវបោះចោល អាចធ្វើឲ្យខូចទ្រង់ទ្រាយបានដោយប្រើផលិតផលសម្អាត (ដូចជាអូសាវែល) ហើយដាក់ក្នុងធុងសំណល់ដែលបិទគម្របនៅខាងក្រៅកន្លែង។
- មួយភាគធំនៃអាហារ គួរតែរក្សាទុកនៅក្នុងតួផ្ទុកសំណល់ដែលបិទគម្របនៅទីតាំងដែលមានសុវត្ថិភាព ហើយចោលដោយក្រុមហ៊ុនចោលសំណល់ ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។
- កាកសំណល់អាហារទាំងអស់ ត្រូវចោលដោយអនុលោមតាមបទប្បញ្ញត្តិនៃការចោលកាកសំណល់របស់រដ្ឋនិងរបស់មូលដ្ឋាន នៅកន្លែងចាក់សំរាមដែលមានអាជ្ញាប័ណ្ណ។
- កន្លែងចាក់សំរាមក្នុងមូលដ្ឋាន គួរតែទាក់ទងមុននឹងដឹកអាហារពីបុគ្គល ឬក្រុមហ៊ុនដឹកជញ្ជូនឯកជន ដើម្បីធានាថាកាកសំណល់នឹងត្រូវបានទទួលយក។

# ការកំពប់សាំងនិងសារធាតុគីមី

## បើមានកំពប់សាំង៖ សាំង

1. កំណត់ភាពធ្ងន់ធ្ងរនៃការកំពប់សាំង។
2. បើការកំពប់សាំងត្រូវបានកំណត់ថាធ្ងន់ធ្ងរ ត្រូវហៅទូរស័ព្ទទៅលេខ911។
3. កំណត់ទីតាំង និងបិទបំពង់សាំង ដោយប្រើកុងតាក់ផ្តាច់អាសន្ន។
4. បើធ្វើបានដោយសុវត្ថិភាព ត្រូវទ្រការកំពប់ និងកាត់បន្ថយការរាលដាលនៃសាំងដោយប្រើភួយ ខ្នើយ និងស្រោមជើងការពារកំពប់។ ធានាតំបន់ដែលកំពប់សាំង ដើម្បីទប់ស្កាត់កង្វក់ និងរក្សាសុវត្ថិភាព។
5. ទាក់ទងទៅអ្នកម៉ៅការសម្អាតការកំពប់របស់អ្នក ដើម្បីទទួលបានជំនួយសម្រាប់ការយកចេញ/សម្អាតកាកសំណល់អន្តរាយ។
    a. អ្នកម៉ៅការសម្អាតការកំពប់ ______________________________
6. ទាក់ទងទៅក្រុមហ៊ុនជួសជុលបំពង់សាំងរបស់អ្នក ឲ្យជួសជុល។
    a. ក្រុមហ៊ុនជួសជុលបំពង់សាំង______________________________
7. ទាក់ទងទៅជួរគ្រប់គ្រងហាង។
8. បើកំពប់ចូលទៅក្នុងបរិស្ថាន ត្រូវទាក់ទងទៅ៖

    **នាយកដ្ឋានពន្លត់អគ្គិភ័យក្រុងប្រូវីដេន ០ 911**

    **នាយកដ្ឋានគ្រប់គ្រងបរិស្ថានរដ្ឋរ៉ូដអាយឡេន (DEM) – (401) 222-4700**
9. ពាក់ឧបករណ៍ការពារផ្ទាល់ខ្លួន (PPE) ដែលសមស្រប ជាប់ជានិច្ចនៅពេលសម្អាតការកំពប់សារធាតុគីមី។

## បើមានកំពប់សារធាតុគីមី៖ ប្រេង សារធាតុទប់ស្កាត់ការកក ថ្នាំលាប អូសាវែល ជាដើម

1. ទ្រផលិតផល ភ្លាមៗ។
2. វាយតម្លៃការកំពប់ ដាក់ឲ្យខ្យល់ចេញចូលនៅតំបន់នោះ ធានាតំបន់ ដាក់ប្រភពឆេះភ្លើងឲ្យនៅឆ្ងាយ។
3. សម្អាតការកំពប់។
    a. បើការកំពប់ធំពេកមិនអាចដោះស្រាយបាន ត្រូវទាក់ទងទៅអ្នកម៉ៅការសម្អាតកាកសំណល់អន្តរាយ។
    b. ពាក់ឧបករណ៍ការពារផ្ទាល់ខ្លួន (ស្រោមដៃ វ៉ែនតាហែលទឹក ស្បែកជើងរុំក្រៅ)។
    c. ស្រូបអង្គធាតុរាវ និងធ្វើឲ្យរឹងដោយប្រើប្រេងស្ងួតឬសារធាតុស្រូបផ្សេងទៀតដែលមាន។

ធ្វើការពីគែមៗឆ្ពោះទៅកណ្តាល។

i. **សូលុយស្យុងទឹក** (ថ្នាំលាបឡាតិច សារធាតុទប់ស្កាត់ការកក អូសាវែល សារធាតុគីមីក្នុងផ្ទះ)

ii. **អាស៊ីត៖** ត្រូវតែបន្សាបដោយប្រើម្សៅសូដាសម្រាន់ដុត

iii. **សូលុយស្យុងប្រេង** (ប្រេងឥន្ធនៈចង្ក្រាន ថ្នាំលាបអេណាម៉េល សារធាតុពង្រាវ/រំលាយ សារធាតុបន្ថែមសាំង/ម៉ាស៊ូត) *កុំប្រើទឹកដើម្បីសម្អាតការកំពប់សូលុយស្យុងប្រេងឲ្យសោះ ប្រើតែសារធាតុស្រូបស្ងួតបានហើយ*

4. ដាក់សម្ភារដែលបានស្រូបដោយប្រុងប្រយ័ត្នទៅក្នុងតួផ្ទុកដែលអាចចោលបាន (ថង់ពីរជាន់ ឬប្រើធុងជ័របិទគម្រប)។
5. ចោលសម្ភារនិងទំនិញដែលបានត្រាំ។ ដុសកន្លែងដែលមានស្នាមប្រឡាក់ និងជ្រុង/ស្នាមក្រហែង។
   a. ចោលសំណល់ជូត សម្ភារសម្អាត អំបោស ស្រោមដៃ ស្បែកជើងរំក្រៅ។ ប្តូរសម្លៀកបំពាក់ និងបោកដោយប្រើសាប៊ូ។

## ករណីប៉ះដោយផ្ទៃជន្ស៖

**ភ្នែក៖** លុបលាងដោយប្រើទឹករយៈពេល 15 នាទី។ ស្វែងរកការព្យាបាលភ្លាមៗ។

**ស្បែក៖** លាងដោយប្រើសាប៊ូនិងទឹក។ មើលស្លាកផលិតផលសម្រាប់ដំបូន្មានបន្ថែម។

**សម្លៀកបំពាក់៖** ដោះសម្លៀកបំពាក់កខ្វក់ចេញ ហើយលាងសម្អាតស្បែកទាំងមូលដោយប្រើសាប៊ូនិងទឹក។

មើលស្លាកផលិតផលសម្រាប់ដំបូន្មានបន្ថែម។

បើអ្នកមានការសង្ស័យអំពីលក្ខណៈរបស់សម្ភារ ត្រូវទទួលការព្យាបាលភ្លាមៗ។

*ចំណាំ៖ បើស្វែងរកការព្យាបាល ត្រូវយកតួផ្ទុកដែលមានស្លាក ទៅឲ្យគ្រូពេទ្យ។*

## រៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់៖

ត្រូវប្រាកដថាបានកត់ត្រា
និងរៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់ដែលកើតឡើងជាលទ្ធផលនៃស្ថានភាពអាសន្ន។

# ការលេចធ្លាយឧស្ម័ននិងប្រេងបែនធម្មជាតិ

## ប៉ាន់ប្រមាណស្ថានការណ៍៖

1. បើអ្នកធុំក្លិនឧស្ម័ន (ក្លិនស្អុយស៊ុតរលួយ) ឬឮសូរសំឡេងស៊ីតៗ ត្រូវសន្មតថាមានលេចធ្លាយ។

កុំប្រើកុងតាក់និងរបស់របរប្រើប្រាស់អគ្គិសនី ឬអណ្តាតភ្លើង ព្រោះវាអាចឆាបឆេះឧស្ម័ន។

2. ជម្លៀសចេញពីតំបន់នោះភ្លាមៗ បើការលេចធ្លាយធ្ងន់ធ្ងរ ឬនៅក្នុងបន្ទប់។ ជួយអ្នកដែលមានតម្រូវការចូល និងតម្រូវការមុខងារ។ **មើលផែនការជម្លៀស នៅខាងលើ សម្រាប់ព័ត៌មានប្រកាស។**
3. **ហៅទូរស័ព្ទទៅលេខ911។**
4. ជូនដំណឹងដល់បុគ្គលិក អ្នកជួល ឬអតិថិជន អំពីស្ថានភាពនិងវិធានការសុវត្ថិភាព។ ពិចារណាពីការជូនដំណឹងជាសាធារណៈ បើការលេចធ្លាយនេះបង្កការគំរាមក្នុងលក្ខណៈទូលំទូលាយ។
5. ធ្វើតាមការណែនាំពីអ្នកឆ្លើយតបបន្ទាន់ ទាក់ទងនឹងការចូលឡើងវិញ ឬការប្រុងប្រយ័ត្នបន្ថែមទៀត។

## ចាត់វិធានការដើម្បីរឹតត្បិតការប៉ះផ្ទាល់ ( បើធ្វើបានដោយមានសុវត្ថិភាព )៖

- **ផ្តាច់ការផ្គត់ផ្គង់ឧស្ម័ន**នៅសន្ទះមេ បើធ្វើបានដោយមានសុវត្ថិភាព។
- **ដាក់ឲ្យមានខ្យល់ចេញចូលនៅតំបន់នោះ** ដោយបើកទ្វារនិងបង្អួច បើនៅខាងក្រៅនិងមានសុវត្ថិភាព។
- ព្រមានអ្នកផ្សេងដែលនៅជិតៗនោះ និងទប់ស្កាត់ប្រភពឆាបឆេះ (ហាមជក់បារី អណ្តាតភ្លើង ឬឧបករណ៍អគ្គិសនី)។
- ទាក់ទងទៅអ្នកផ្គត់ផ្គង់របស់របរប្រើប្រាស់ឧស្ម័ន ដើម្បីរាយការណ៍ពីការលេចធ្លាយ។

## រៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់៖

ត្រូវប្រាកដថាបានកត់ត្រា
និងរៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់ដែលកើតឡើងជាលទ្ធផលនៃស្ថានភាពអាសន្ន។

# សារធាតុសង្ស័យ (កញ្ចប់ និង សំបុត្រ)

**កុំហិត ប៉ះ ឬផ្លាស់ទី សារធាតុសង្ស័យ (កញ្ចប់និងសំបុត្រ)។**

**កុំផ្លាស់ប្តូរបរិស្ថាន រួមទាំងពន្លឺផងដែរ។**

កំណត់ថាតើមានការគំរាមកំហែងច្បាស់ៗ មានបង្កប់ការគំរាម ឬមានហានិភ័យ ចំពោះមនុស្ស ឬបរិស្ថានឬទេ។

ការគំរាមដែលបានទទួលតាមទូរសព្ទ សារអ៊ីម៉េលជាដើម
ដែលអាចបង្ហាញពីចេតនាដាក់សារធាតុគ្រោះថ្នាក់អន្តរាយនៅក្នុងកន្លែង និង/ឬ នៅលើផលិតផល។

## ប្រសិនបើប្រភពស្របច្បាប់នៃសារធាតុមិនអាចកំណត់អត្តសញ្ញាណបាន ឬមានកាលៈទេសៈគំរាមកំហែង៖

1. ហៅទូរស័ព្ទទៅលេខ911។
2. បើធ្វើបានដោយមានសុវត្ថិភាព ត្រូវធានាតំបន់ជុំវិញសារធាតុ និង/ឬផលិតផលសង្ស័យ។
3. ជម្លៀសចេញពីតំបន់។ មើលផែនការជម្លៀស នៅខាងលើ។
4. កំណត់វិសាលភាពនៃគ្រោះថ្នាក់អន្តរាយ។
    a. រៀបចំឯកសារអំពីព័ត៌មានពាក់ព័ន្ធនឹងសារធាតុសង្ស័យ។
    b. បើធ្វើបានដោយមានសុវត្ថិភាព ត្រូវស៊ើបអង្កេតប្រភពស្របច្បាប់នៃសារធាតុ (ម្សៅ ម្សៅស្ងួតសម្រាប់ដុត ម្សៅលាបខ្លួន ជាដើម)។
    c. ផ្តល់បញ្ជីរាយនាមមនុស្ស លំហ និងវត្ថុទាំងអស់ដែលបានប៉ះផ្ទាល់ ទៅឲ្យសមត្ថកិច្ច។
5. កំណត់ថាអ្នកណាខ្លះដែលប្រហែលជាបានប៉ះនឹងសារធាតុ។
    a. បុគ្គលដែលប្រហែលជាបានប៉ះផ្ទាល់ គួរតែរៀបចំដាក់នៅក្នុងតំបន់ដែលឆ្ងាយពីអ្នកផ្សេង។
    b. ធ្វើតាមការណែនាំពីការសម្អាតភាពកខ្វក់ ពីមន្ត្រីសេវាកម្មសុវត្ថិភាពសាធារណៈដែលឆ្លើយតប។
6. កំណត់ពីតម្រូវការហៅប្រមូលផលិតផលមកវិញ។
7. កំណត់ថាតើព័ត៌មានណាខ្លះនឹងចេញផ្សាយជាសាធារណៈ ដោយសម្របសម្រួលជាមួយមន្ត្រីសុវត្ថិភាពសាធារណៈ។
8. ទាក់ទង (កំណត់អត្តសញ្ញាណជាមុន) ទៅអ្នកជំនាញប្រធានបទនោះ/ចំណុចនៃមធ្យោបាយទាក់ទង (ឈ្មោះ មុខតំណែង លេខទូរសព្ទ)។
    a. ______________________________
    b. ______________________________
    c. ______________________________

## ប្រសិនបើសារធាតុត្រូវបានកំណត់ថាមិនមានគ្រោះថ្នាក់អន្តរាយ៖

1. ចាត់វិធានការសមស្របដើម្បីយកចេញ និងសម្អាតតំបន់/ផលិតផល។
2. ទាក់ទងពីការរកឃើញ ទៅកាន់អតិថិជននិងបុគ្គលិកដែលមានអាចរងផលប៉ះពាល់។

## រៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់៖

ត្រូវប្រាកដថាបានកត់ត្រា
និងរៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់ដែលកើតឡើងជាលទ្ធផលនៃស្ថានភាពអាសន្ន។

# ចលាចលស៊ីវិល

## បិទកន្លែងប្រសិនបើមានការណែនាំពីស្រុក/តំបន់/សាជីវកម្ម/អាជ្ញាធរស៊ីវិល៖

1. ជម្លៀសភ្ញៀវនិងបុគ្គលិកទាំងអស់ មិនសំខាន់ក្នុងការចាត់ការលើការបិទនោះទេ។ មើលផែនការជម្លៀស នៅខាងលើ។

2. ចាត់ការលើការបិទ។ មើលផែនការជម្លៀស នៅខាងលើ។
3. ការពារលុយនិងទំនិញ។
4. ធានាសុវត្ថិភាពហាង។

## ការពារលុយនិងទំនិញ បើធ្វើបែបនេះមិនគំរាមដល់សុវត្ថិភាពរបស់នរណាម្នាក់ទេ៖

1. បិទនិងចាក់សោម៉ាស៊ីនទូទាត់ចេញក្រៅ និងម៉ាស៊ីនគិតលុយទាំងអស់។
2. ចាក់សោប្រអប់សុវត្ថិភាពបន្ទប់ដាក់លុយ/គ្រប់គ្រង និងចាក់សោទ្វារទៅបន្ទប់ដាក់លុយ/គ្រប់គ្រង។

## ធានាសុវត្ថិភាពហាងសម្រាប់ចលាចលស៊ីវិល៖

1. បើកភ្លើងបំភ្លឺចំណតទាំងអស់ ហើយបិទភ្លើងបំភ្លឺខាងក្នុងទាំងអស់។ បើមានកាមេរ៉ាដែលអាចប្រើបាន ត្រូវប្រាកដថាកាមេរ៉ាទាំងនោះកំពុងថត។
2. អនុវត្តនីតិវិធីដំឡើងរបាំងតាមការណែនាំ។
3. ធានាសុវត្ថិភាពប្រឡោះនៅជុំវិញបរិមាត្រទាំងអស់៖
    a. ទ្វារអគ្គិភ័យ
    b. គម្របដំបូល
    c. ទ្វារការ៉ាស់
4. ប្រមូលបំពង់ពន្លត់អគ្គិភ័យទាំងអស់ ហើយដាក់នៅជិតច្រកចូលនីមួយៗ។
5. ពិនិត្យទីតាំងពិល និងដាក់ថ្មថ្មី។
6. កំណត់កណ្ដឹងរោទ៍របស់ហាងទាំងអស់។

7. ត្រូវប្រាកដថាសន្ទះក្បាលបាញ់ស្រោចទាំងអស់ ត្រូវបានចាក់សោនៅទីតាំង "បើក"។
8. ដកក្តារក្រដាសក្រាលអីវ៉ាន់ និងវត្ថុងាយឆេះផ្សេងទៀត ចេញពីជុំវិញខាងក្រៅអាគារ។

## រៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់៖

ត្រូវប្រាកដថាបានកត់ត្រា
និងរៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់ដែលកើតឡើងជាលទ្ធផលនៃស្ថានភាពអាសន្ន។

# ការគំរាមបំផ្ទុះគ្រាប់បែក

## ប្រតិកម្មនឹងការគំរាមបំផ្ទុះគ្រាប់បែក ឲ្យបានលឿននិងស្ងប់ស្ងៀម៖

1. ហៅទូរស័ព្ទទៅលេខ911។
2. ប្រើប្រាស់ទម្រង់របាយការណ៍ហេតុការណ៍របស់អ្នក និងកត់ត្រាព័ត៌មានទាំងអស់។
3. ផ្តាច់ឧបករណ៍អេឡិចត្រូនិចខាងក្រោមនេះ (ដូចជា)៖
    a. ប្រព័ន្ធឧបករណ៍ទូរគមនាគមន៍ទទួលសារ
    b. ប្រព័ន្ធប្រកាសប្រាប់អាសន្ន (EAS) (ឧទាហរណ៍៖ ប្រព័ន្ធជូនដំណឹងទ្រង់ទ្រាយធំ ប្រព័ន្ធផ្សព្វផ្សាយសាធារណៈ(PA) ប្រព័ន្ធប្រកាសសារអាសន្ន)
    c. វិទ្យុពីរទិស
    d. ទូរសព្ទដៃ
    e. ប្រព័ន្ធប្រេកង់វិទ្យុ
4. ទាក់ទងទៅមធ្យោបាយទាក់ទងអាសន្នបុគ្គលិក ប្រសិនបើចាំបាច់។

## ចំណាំ៖

ការស្រាវជ្រាវនឹងធ្វើឡើងដោយមានការសម្របសម្រួលជាមួយនាយកដ្ឋានប៉ូលីស។
កុំចាប់ផ្តើមការស្រាវជ្រាវដោយខ្លួនឯង។ អ្នកអាចត្រូវបានស្នើសុំដោយអាជ្ញាធរស៊ីវិលឲ្យជួយក្នុងការស្រាវជ្រាវ។

## ជម្លៀសចេញពីអគារ ប្រសិនបើ៖

- រកឃើញវត្ថុដែលសង្ស័យថាជាឧបករណ៍បំផ្ទុះនៅក្នុងអគារ។
- អាជ្ញាធរមូលដ្ឋានបញ្ជាឲ្យមានការជម្លៀសចេញ។
- ទទួលបានការគំរាមបំផ្ទុះគ្រាប់បែកលើកទីពីរ ក្នុងរយៈពេលដែលអ្នកគេបានបញ្ជាក់ ហើយការស្រាវជ្រាវមិនទាន់បញ្ចប់។

- សុវត្ថិភាពរបស់ភ្ញៀវនិងបុគ្គលិក រងការគំរាម។

**មើលផែនការជម្លៀស នៅខាងលើ។ + មើលបញ្ជីពិនិត្យការគំរាមបំផ្ទុះគ្រាប់បែកនៅក្នុងឧបសម្ព័ន្ធD។**

# ការដាច់ភ្លើង

## បើមានការដាច់ភ្លើង៖

1. ផ្តល់ពិលទៅឲ្យមនុស្សឲ្យបានច្រើននាក់តាមដែលអាចធ្វើទៅបាន។
2. ពិនិត្យរកមើលភ្ញៀវឬបុគ្គលិកដែលជាប់ នៅគ្រប់តំបន់តាមដែលអាចធ្វើបាន រួមទាំងជណ្តើរយន្តប្រអប់ផងដែរ។
3. កំណត់ថាតើអ្នកត្រូវការជម្លៀសចេញពីអាគារឬទេ (មើលផែនការជម្លៀស)។
4. ទាក់ទងទៅមធ្យោបាយទាក់ទងអាសន្នបុគ្គលិក ប្រសិនបើចាំបាច់។

## ប្រសិនបើការដាច់ភ្លើងប៉ះពាល់ដល់ទីតាំងអគារ និងតំបន់ជុំវិញនៅក្នុងសហគមន៍របស់អ្នក៖

- សួរក្រុមហ៊ុនថាមពល ថាពេលណាដែលគេរំពឹងថាសេវាកម្មអគ្គិសនីនឹងត្រូវបានស្តារឡើងវិញ។
- ផ្តាច់ឧបករណ៍ និងកុំប្រេសស័រ ដែលអាចនឹងខូចនៅពេលដែលភ្លើងត្រឡប់មកវិញ។
- គ្របរបស់ក្លាសេដែលអាចខូចទាំងអស់ ហើយដាក់ទ្វាររបស់ទូរទឹកកកដើរចូលបាន/ទូរកកឲ្យបិទជិត។

## ប្រសិនបើការដាច់ភ្លើងប៉ះពាល់តែទៅលើទីតាំងអគាររបស់អ្នក៖

- ធ្វើការត្រួតពិនិត្យទីតាំងផ្ទាល់ ដើម្បីកំណត់ពីមូលហេតុជាក់ច្បាស់នៃការដាច់ភ្លើង។
- ផ្តាច់ឧបករណ៍ និងកុំប្រេសស័រ ដែលអាចនឹងខូចនៅពេលដែលភ្លើងត្រឡប់មកវិញ។
- គ្របរបស់ក្លាសេដែលអាចខូចទាំងអស់ ហើយដាក់ទ្វាររបស់ទូរទឹកកកដើរចូលបាន/ទូរកកឲ្យបិទជិត។
- ហៅទូរស័ព្ទទៅក្រុមហ៊ុនថាមពលក្នុងមូលដ្ឋានរបស់អ្នកដើម្បីភ្ជាប់ភ្លើងមកវិញ។

## រៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់៖

ត្រូវប្រាកដថាបានកត់ត្រា
និងរៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់ដែលកើតឡើងជាលទ្ធផលនៃស្ថានភាពអាសន្ន។

# កង្វក់ទឹក និង ការផ្តល់យោបល់ពីការដាំទឹក

បើអ្នកត្រូវបានគេប្រាប់ថាទឹករងកង្វក់ ឬ
បើនាយកដ្ឋានទឹកក្នុងមូលដ្ឋានឬក្នុងក្រុងបានប្រកាសការផ្តល់យោបល់ពីការដាំទឹក៖

**ហៅទូរស័ព្ទទៅជួរគ្រប់គ្រងហាង និងទាក់ទងទៅមន្ត្រីបាយអាសន្នបុគ្គលិក ប្រសិនបើចាំបាច់។**

## ទឹកកកនិងភេសជ្ជៈ

- ផ្តាច់ម៉ាស៊ីនផលិតសូដា ទឹកកក ទឹកផឹក និងចំហាយទឹកជាដើម។
- បំផ្លាញទឹកកកទាំងអស់នៅក្នុងធុងដាក់។ ប្រើតែទឹកកកពាណិជ្ជកម្មបានហើយ។
- ផ្តាច់ម៉ាស៊ីនឆុងកាហ្វេនិងតែទឹកកក និងរ៉ូប៊ីណេទឹកផឹក។

## ការរៀបចំអាហារ និងចម្អិនអាហារ

- ចោលអាហារត្រៀមហូបបាន ដែលបានរៀបចំដោយប្រើទឹកមុនពេលរកឃើញកង្វក់។
- ប្រើផលិតផលលាងមុន ឬលាងដោយទឹកឆ្អិន ឬទឹកសុទ្ធដប។
- រៀបចំអាហារត្រៀមហូបបាន ដោយប្រើទឹកសុទ្ធដបពាណិជ្ជកម្ម ឬទឹកឆ្អិន*។
- ប្រើទឹកសុទ្ធដបដែលមានសុវត្ថិភាព ឬទឹកដែលយកពីការផ្គត់ផ្គង់ទឹកសាធារណៈដែលត្រូវបានអនុញ្ញាត សម្រាប់ចម្អិនអាហារ។

## ការលាងដៃ

- ប្រើទឹកសុទ្ធដបដែលបានកម្តៅ ទឹកឆ្អិន ឬទឹកដែលយកពីការផ្គត់ផ្គង់ទឹកសាធារណៈដែលត្រូវបានអនុញ្ញាត។
- ឬ ប្រើទឹកម៉ាស៊ីន ហើយប្រើសារធាតុរក្សាអនាម័យដៃតាមក្រោយ។
- ត្រូវប្រាកដថាបានប្រើស្រោមដៃនៅពេលចាប់អាហារត្រៀមហូបបាន។

## ការសម្អាតនិងការរក្សាអនាម័យ

- ប្រើប្រព័ន្ធដែលមានស្រាប់។ ត្រូវប្រាកដថា សារធាតុរក្សាអនាម័យមានកំហាប់ត្រឹមត្រូវ។

## ក្រោយកង្វក់ និង ការដាំឲ្យពុះ

- បើកបង្ហូរទឹកក្បាលរ៉ូប៊ីណេ កំសៀវឆុងកាហ្វេ រ៉ូប៊ីណេទឹកផឹក ម៉ាស៊ីនភេសជ្ជៈ យ៉ាងហោចណាស់ 5 នាទី។
- សម្អាត និងរក្សាអនាម័យឧបករណ៍កាហ្វេនិងភេសជ្ជៈ ទៅតាមការណែនាំរបស់ក្រុមហ៊ុនផលិត។

- បើឧបករណ៍មានតម្រងខាងក្នុង គួរតែប្តូរជំនួសតម្រងនោះ។

### ម៉ាស៊ីនធ្វើទឹកកក៖

- បើកបង្ហូរខ្សែទឹក ទៅកាន់ប្រឡោះចូលម៉ាស៊ីនធ្វើទឹកកក។
- បិទសន្ទះលើខ្សែទឹកនៅខាងក្រោយម៉ាស៊ីន ហើយផ្តាច់ខ្សែទឹកចេញពីប្រឡោះចូលម៉ាស៊ីន។
- ភ្ជាប់ខ្សែទឹកទៅច្រកចូលម៉ាស៊ីនឡើងវិញ។
- បើកសន្ទះ។
- បើកបង្ហូរខ្សែទឹកនៅក្នុងម៉ាស៊ីន។
- ធ្វើទឹកកករយៈពេលមួយម៉ោង រួចចោលទឹកកកនោះ។

### ការដាំទឹក

1. ដាក់ទឹកក្នុងកំសៀវឬតួផ្ទុកដែលស្អាត និងត្រូវបានរក្សាអនាម័យ។
2. ដាំទឹកដាំឲ្យពុះ ដោយប្រើចង្រ្កានភ្លើង។
3. ទុកឲ្យទឹកពុះគ្រាក់ៗ យ៉ាងហោចណាស់ប្រាំ (5) នាទី។
4. បន្ទាប់ពី 5 នាទី បើចាំបាច់ ទុកឲ្យទឹកត្រជាក់ដោយដាក់វានៅក្នុងតួផ្ទុកមួយផ្សេងទៀតដែលត្រូវបានរក្សាអនាម័យ

# ការបែកបំពង់ទឹក

### បើបំពង់ទឹកបែក៖

1. កំណត់ថាតើបំពង់ទឹកនោះជាផ្នែកនៃប្រព័ន្ធក្នុង ឬប្រព័ន្ធក្បាលបាញ់ស្រោចពន្លត់អគ្គិភ័យ។
    a. បំពង់ក្បាលបាញ់ស្រោចពន្លត់អគ្គិភ័យ ជារឿយៗត្រូវបានដាក់ស្លាកថា "ការពារអគ្គិភ័យ" ឬ "ប្រព័ន្ធក្បាលបាញ់ស្រោច" ជាអក្សរពណ៌ក្រហម ឬ ស។
    b. បំពង់ទឹកក្នុង អាចមានដាក់ស្លាកថា "ទឹកចល័ត" ឬមានសញ្ញាពណ៌ខៀវ/បៃតង។
2. កំណត់ទីតាំង និងបិទសន្ទះដែលគ្រប់គ្រងប្រភពទឹកទៅកាន់ផ្នែកមេ។

3. ទាក់ទងទៅអ្នកផ្គត់ផ្គង់ទឹកប្រើប្រាស់ ដើម្បីទទួលបានជំនួយ ប្រសិនបើប្រើទឹកក្រុង។
    - ផ្តល់ព័ត៌មានលម្អិតអំពីប្រភេទបំពង់ទឹកដែលខូច។
    - ត្រូវប្រាកដថាបានប្រាប់គេ ប្រសិនបើអ្នកបានបិទផ្នែកមេរបស់ក្បាលបាញ់ស្រោចពន្លត់អគ្គិភ័យ។
4. បិទចរន្តអគ្គិសនីទៅកាន់លំហដែលរងផលប៉ះពាល់ នៅឌីស្យុងទ័រសៀគ្វី ភ្លាមៗ បើធ្វើបានដោយមានសុវត្ថិភាព។ កុំចូលក្នុងទឹក បើអាចមានព្រីភ្លើង របស់របរប្រើប្រាស់អគ្គិសនី ឬខ្សែភ្លើង ត្រាំក្នុងទឹក។
5. ហៅទូរសព្ទទៅមធ្យោបាយទាក់ទងអាសន្នបុគ្គលិក បើចាំបាច់។

## នៅពេលផ្នែកមេទឹក ត្រូវបានបិទ៖

1. លាងសម្អាតទឹក។
    a. ប្រយ័ត្នគ្រោះថ្នាក់អន្តរាយផ្នែកអគ្គិសនី។
2. លើកទំនិញឲ្យផុតពីកម្រាលឥដ្ឋ ដើម្បីទប់ស្កាត់ការខូចខាតដោយសារទឹក។
3. រុញទឹកចេញពីអាគារ ឬបង្ហូរចុះក្រោម ដោយប្រើប្រដាប់រុញទឹក អំបោស ប្រដាប់ជូតឥដ្ឋ ឬច្រាស។
4. ជូនដំណឹងដល់ម្ចាស់ដី ឬជាងភ្លើងផ្ទាល់របស់អ្នក ឲ្យត្រួតពិនិត្យ/ស្តារអគ្គិសនីឡើងវិញ។

## រៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់៖

ត្រូវប្រាកដថាបានកត់ត្រា
និងរៀបចំឯកសារអំពីហេតុការណ៍/ការចំណាយទាំងអស់ដែលកើតឡើងជាលទ្ធផលនៃស្ថានភាពអាសន្ន។

# ការដាច់ប្រព័ន្ធភ្លាសេ និង សុវត្ថិភាពអាហារ

## ប្រសិនបើដាច់ប្រព័ន្ធភ្លាសេ ឬប្រព័ន្ធរក្សាកម្តៅ៖

1. ព្យាយាមស្វែងរកប្រភពនៃការដាច់។
2. ប្រកាសប្រាប់បុគ្គលិកនៅក្នុងតំបន់នោះ។
3. ផ្អាកលក់ផលិតផលដែលរងផលប៉ះពាល់។
4. ព័ទ្ធបិទតំបន់ដែលរងផលប៉ះពាល់។
5. ចាប់ផ្តើមប្រតិបត្តិការតាមដានសីតុណ្ហភាព។
6. ទាក់ទងទៅអ្នកផ្គត់ផ្គង់សេវាដែលសមស្រប។
7. ទាក់ទងទៅមធ្យោបាយទាក់ទងអាសន្នបុគ្គលិករបស់អ្នក ប្រសិនបើចាំបាច់។
8. ចាប់ផ្តើមធ្វើតាមជំហានខាងក្រោមរហូតទាល់តែសីតុណ្ហភាពត្រឡប់មកកម្រិតធម្មតាវិញ។

## អ្វីដែលអ្នកគួរធ្វើនៅពេលមានការគំរាមពីការដាច់ភ្លើង៖

ធ្វើសកម្មភាពរក្សាអាហារក្តៅឲ្យនៅក្តៅ និងអាហារត្រជាក់ឲ្យនៅត្រជាក់។ កំណត់ដាក់ទូរទឹកកក និងទូរកកទៅការកំណត់ដែលត្រជាក់បំផុត។ នៅពេលដែលភ្លើងដាច់ គួរតែកត់ពេលវេលា។

## អ្វីដែលអ្នកគួរធ្វើនៅពេលភ្លើងដាច់៖

គោលដៅគឺរក្សាអាហារក្តៅឲ្យនៅលើសពី 135°F និងអាហារត្រជាក់ឲ្យនៅក្រោម 40°F
ឲ្យបានយូរបំផុតតាមដែលអាចធ្វើទៅបាន
និងតាមដានសីតុណ្ហភាពដើម្បីកំណត់ថាពេលណាអាហារលែងមានសុវត្ថិភាពក្នុងការទទួលទាន។

### <u>អាហារក្តៅ</u>

- កុំដាក់អាហារក្តៅក្នុងទូរទឹកកក ឬទូរកក។
- ប្រើ "កំប៉ុងកម្តៅ" ដាក់ក្រោមអាហារ នៅលើតុចំហុយអគ្គិសនី ដើម្បីជួយរក្សាសីតុណ្ហភាពអប្បបរមា 135°F។

### <u>អាហារត្រជាក់</u>

- បិទទ្វារទូរទឹកកក និងទូរកកឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន។
- បើអាចអនុវត្តបាន ត្រូវញែកកញ្ចប់អាហារត្រជាក់ឲ្យនៅជាមួយគ្នា ដើម្បីកាត់បន្ថយការឡើងកម្តៅ។
- គ្របប្រអប់អាហារក្លាសេនិងអាហារបង្អែកដែលចំហ ជាពិសេសប្រអប់បើកបញ្ឈរ។

*ប្រយ័ត្ន៖ ការប្រើទឹកកកស្ងួតដើម្បីធ្វើឲ្យអាហារត្រជាក់ អាចបណ្តាលឲ្យមានការបង្កើតកាបូនឌីអុកស៊ីត (CO2) ដែលមិនមានសុវត្ថិភាព។*

## កុំរៀបចំអាហារ ប្រសិនបើអ្នកមិនចេះ៖

- សម្អាត លាងជម្រះ និងរក្សាអនាម័យរបស់របរប្រើប្រាស់ឲ្យបានត្រឹមត្រូវ។
- ដាក់ដំណើរការប្រហោងខ្យល់ចេញចូលសម្រាប់ចម្អិនអាហារ និងប្រព័ន្ធផ្គត់ផ្គង់ខ្យល់ពីក្រៅ (ផ្សែងពុលអាចបណ្តាលឲ្យមានរបួស ឬស្លាប់)។
- បំភ្លឺតំបន់រៀបចំអាហារឲ្យមានពន្លឺគ្រប់គ្រាន់ ដើម្បីឲ្យអាចរៀបចំអាហារ សម្អាត និងរក្សាអនាម័យបានដោយសុវត្ថិភាព។
- ចូលប្រើទឹកក្តៅ ឬសម្អាធទឹកដែលសមល្មម។
- រក្សាសីតុណ្ហភាពអាហារដែលមានសុវត្ថិភាព។

## អ្វីដែលអ្នកគួរធ្វើនៅពេលភ្លើងត្រឡប់មកវិញ៖

- ពិនិត្យសីតុណ្ហភាពអាហារខាងក្នុង។
- បើអាចអនុវត្តបាន ត្រូវញែកកញ្ចប់អាហារនៅក្នុងទូរទឹកកក និងទូរកក ដើម្បីឲ្យត្រជាក់លឿនជាងមុន។
- ចោលអាហារដែលអាចនឹងគ្រោះថ្នាក់អន្តរាយ ដែលប្រហែលជាស្ថិតក្នុងតំបន់សីតុណ្ហភាពគ្រោះថ្នាក់។

## កំណត់ថាតើអាហារដែលអាចនឹងគ្រោះថ្នាក់អន្តរាយ មានសុវត្ថិភាពឬទេ៖

### អាហារក្តៅ

- បើដាច់ភ្លើងរយៈពេល 2 ម៉ោង ឬតិចជាងនេះ ហើយសីតុណ្ហភាពអាហារមានសីតុណ្ហភាពក្រោម 135°F នោះអាចនឹងលក់បានបើកម្តៅវាឡើងវិញដល់ 165°F ហើយបន្ទាប់មករក្សានៅសីតុណ្ហភាព 135°F ឡើងលើ ឬ បើវាត្រូវបានបញ្ចុះឲ្យត្រជាក់យ៉ាងលឿនដល់ 41°F ឬក្រោមនេះ ក្នុងរយៈពេល 2 ម៉ោងបន្ទាប់ពីភ្លើងមកវិញ។
- បើដាច់ភ្លើងរយៈពេលលើសពី 2 ម៉ោង នោះអាហារមិនអាចលក់បានទេ។

### អាហារត្រជាក់

- បើដាច់ភ្លើងរយៈពេលតិចជាង 2 ម៉ោង ហើយអាហារមានសីតុណ្ហភាព 45°F ឬក្រោមនេះ នោះអាចលក់បាន។ បើវាស្ថិតនៅចន្លោះពី 46°F ដល់ 50°F ត្រូវបញ្ចុះឲ្យវាត្រជាក់ភ្លាមៗដល់ 41°F ឬក្រោមនេះ ក្នុងរយៈពេល 2 ម៉ោង។
- បើដាច់ភ្លើងរយៈពេលពី 2 ទៅ 4 ម៉ោង នោះអាហារអាចលក់បានបើវាមានសីតុណ្ហភាពក្រោម 45°F ប៉ុន្តែត្រូវតែបញ្ចុះវាឲ្យត្រជាក់ដល់ 41°F ឬក្រោមនេះ ក្នុងរយៈពេល 2 ម៉ោង។ បើអាហារស្ថិតនៅចន្លោះពី 46°F ទៅ 50°F នោះត្រូវតែបញ្ចុះឲ្យវាត្រជាក់ដល់ 41°F ឬក្រោមនេះ ក្នុងរយៈពេល 1 ម៉ោង។ បើវាក្តៅជាង 50 ° F នោះមិនអាចលក់បានទេ។
- បើដាច់ភ្លើងរយៈពេល 4 ម៉ោង ឬលើសនេះ នោះអាហារអាចលក់បានបើវាមានសីតុណ្ហភាព 45°F ឬក្រោមនេះ និងត្រូវបានបញ្ចុះឲ្យត្រជាក់ដល់ 41°F ឬក្រោមនេះ ក្នុងរយៈពេល 1 ម៉ោង។ បើវាក្តៅជាង 45 ° F នោះមិនអាចលក់បានទេ។

## ចោលអាហារដែលគ្មានសុវត្ថិភាព៖

ពេលដែលមានការសង្ស័យ ចូរបោះវាចោល។ បើបានកំណត់ថាត្រូវចោលអាហារ ត្រូវរៀបចំឯកសារអំពីប្រភេទនិងបរិមាណអាហារ និងហេតុផលនៃការចោល សម្រាប់គោលបំណងធានារ៉ាប់រង និងបទប្បញ្ញត្តិ។ មួយភាគតូចនៃអាហារដែលត្រូវបោះចោល

អាចធ្វើឲ្យខូចទ្រង់ទ្រាយបានដោយប្រើផលិតផលសម្អាត (ដូចជាអូសាវែល) ហើយដាក់ក្នុងធុងសំណល់ដែលបិទគម្របនៅខាងក្រៅ។ ដើម្បីចោលមួយភាគធំនៃអាហារ ត្រូវទាក់ទងទៅក្រុមហ៊ុនចោលសំណល់របស់អ្នក ឬប្រតិបត្តិករចាក់សំរាមនៅក្នុងមូលដ្ឋានរបស់អ្នក ដើម្បីទទួលបានការណែនាំពីការចោល។

## ត្រឡប់ទៅធម្មតាវិញ៖

លក្ខខណ្ឌខាងក្រោមគួរតែត្រូវបានផ្ទៀងផ្ទាត់ជាមុនសិន មុននឹងចាប់ផ្តើមរៀបចំអាហារឡើងវិញ និង/ឬលក់អាហារដែលអាចនឹងមានគ្រោះថ្នាក់អន្តរាយ៖

- អាហារដែលអាចនឹងមានគ្រោះថ្នាក់អន្តរាយ ដែលគ្មានសុវត្ថិភាពទាំងអស់ ត្រូវបានចោលរួចហើយ។
- សេវាកម្មអគ្គិសនីនិងឧស្ម័ន បានត្រឡប់មកវិញហើយ។
- ឌីស្ប៉ុងទ័រសៀគ្វីទាំងអស់ ត្រូវបានកំណត់ឡើងវិញបានយ៉ាងត្រឹមត្រូវទៅតាមតម្រូវការរួចហើយ។
- ឧបករណ៍និងបរិក្ខារទាំងអស់ មានដំណើរការបានត្រឹមត្រូវហើយ ដូចជាភ្លើងបំភ្លឺ បរិក្ខារត្លាសេ រក្សាកម្តៅ ខ្យល់ចេញចូល បង្គន់។
- ទឹកផឹកក្តៅនិងត្រជាក់ ក្រោមសម្ពាធសម្រាប់ការលាងដៃ ការលាងចានបានសមស្រប។

*បើកន្លែងរបស់អ្នកត្រូវបានបិទដោយនាយកដ្ឋានសុខាភិបាល*
*នោះត្រូវតែបិទរហូតទាល់តែអ្នកទទួលបានការយល់ព្រមជាផ្លូវការពីនាយកដ្ឋានដើម្បីបើកឡើងវិញ។*

# 3. ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធA – ផែនការផ្លូវជម្លៀសចេញពីកន្លែង

# ឧបសម្ព័ន្ធB – សេវាកម្មអាសន្នសាធារណៈនិងអ្នកម៉ៅការ

| សេវាកម្មអាសន្ន | ឈ្មោះ | លេខទូរសព្ទអាសន្ន | លេខទូរសព្ទអាជីវកម្ម |
|---|---|---|---|
| នាយកដ្ឋានពន្លត់អគ្គិភ័យ | នាយកដ្ឋានពន្លត់អគ្គិភ័យក្រុងប្រូវីដេន | 911 | 401-243-6060 |
| សេវាកម្មវេជ្ជសាស្ត្រអាសន្ន | នាយកដ្ឋានពន្លត់អគ្គិភ័យក្រុងប្រូវីដេន | 911 | 401-243-6060 |
| នាយកដ្ឋានប៉ូលីស | នាយកដ្ឋានពន្លត់អគ្គិភ័យក្រុងប្រូវីដេន | 911 | 401-272-3121 |
| ទីភ្នាក់ងារគ្រប់គ្រងអាសន្ន | **PEMA** | 911 | 401-680-8000 |
| មន្ទីរពេទ្យ | មន្ទីរពេទ្យរ៉ូដអាយឡេន | 401-444-4000 | 401-444-4000 |
| នាយកដ្ឋានសុខាភិបាលរដ្ឋរ៉ូដអាយឡេន | **RIDOH** | 401-222-7745 | 401-222-5960 |
| នាយកដ្ឋានគ្រប់គ្រងបរិស្ថានរដ្ឋរ៉ូដអាយឡេន | **RDEM** | 401-222-3070 | 401-222-1360 |
| បណ្ដាលជាតិ (ឧស្ម័ន) | បណ្ដាលជាតិ | 800-640-1595 / 911 | 800-870-1664 |
| បណ្ដាលជាតិ (អគ្គិសនី) | បណ្ដាលជាតិ | 800-465-1212 | 800-322-3223 |
| ជាងភ្លើង | | | |
| ជាងបំពង់ទឹក | | | |
| អ្នកម៉ៅការការពារអគ្គិភ័យ | | | |
| អ្នកម៉ៅការប្រព័ន្ធកម្ដៅ ខ្យល់ចេញចូល និងម៉ាស៊ីនត្រជាក់ | | | |
| សេវាកម្មជណ្ដើរយន្តប្រអប់ | | | |
| ការសម្អាតសារធាតុគ្រោះថ្នាក់អន្តរាយ | | | |
| ការសម្អាត និងការស្ដារគ្រោះមហន្តរាយ | | | |
| អ្នកម៉ៅការ **IT** | | | |

| | | | |
|---|---|---|---|
| **អ្នកម៉ៅការប្រព័ន្ធភ្លាសេ** | | | |
| **កុងតឺណ័រភ្លាសេ** | | | |
| **ឧបករណ៍ជួល** | | | |
| **ប្រព័ន្ធសន្តិសុខ /CCTV** | | | |

# ឧបសម្ព័ន្ធC – ក្រុមការងារឆ្លើយតបអាសន្ន (ERT)

## <u>ក្រុមការងារឆ្លើយតបអាសន្ន</u>

កំណត់អត្តសញ្ញាណសមាជិកនៃក្រុមការងារឆ្លើយតបអាសន្ន ដែលមិនត្រូវបានកំណត់អត្តសញ្ញាណនៅកន្លែងផ្សេង។

- បុគ្គលិកគ្រប់គ្រងកន្លែងឬអគារ ដែលស្គាល់ពីរបស់របរប្រើប្រាស់ និងប្រព័ន្ធការពារក្នុងអគារ និងបុគ្គលដែលអាចនឹងជួយក្នុងសកម្មភាពអភិរក្សទ្រព្យសម្បត្តិ
- សន្តិសុខ
- បុគ្គលផ្សេងទៀតដែលត្រូវបានបណ្តុះបណ្តាលឲ្យប្រើបំពង់ពន្លត់អគ្គិភ័យ និងសម្អាតការកំពប់តូចៗនៃសារធាតុគ្រោះថ្នាក់អន្តរាយ

| ក្រុមការងារ | ឈ្មោះសមាជិក | លេខទូរសព្ទការងារ | លេខទូរសព្ទផ្ទាល់ខ្លួន |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

| | | | |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

## ឧបសម្ព័ន្ធD – បញ្ជីពិនិត្យការគំរាមបំផ្ទុះគ្រាប់បែក

- ដោនឡូតឯកសារPDF តាមរយៈ [CISA](CISA) ។

**BOMB THREAT PROCEDURES**

*This quick reference checklist is designed to help employees and decision makers of commercial facilities, schools, etc. respond to a bomb threat in an orderly and controlled manner with the first responders and other stakeholders.*

Most bomb threats are received by phone. Bomb threats are serious until proven otherwise. Act quickly, but remain calm and obtain information with the checklist on the reverse of this card.

**If a bomb threat is received by phone:**

- Remain calm & do not hang up, keep the caller on the line for as long as possible
- If possible, signal other staff members to listen & notify Site Decision Maker(s)
- If the phone has a display, copy the number and/or letters on the display
- Write down the exact wording of the threat
- Record the call, if possible
- Fill out the Bomb Threat Checklist immediately

**If you receive a written threat:**

- Handle the document as little as possible
- Note date, time, and location the document was found
- Secure the document and do not alter the item in any way
- Notify the organization Site Decision Maker(s)

**If you receive a social media or email threat:**

- Do not turn off or log out of the account
- Leave the message open on the device
- Take a screenshot, or copy the message and subject line
- Note the date and time
- Notify the organization Site Decision Maker(s)

**** Refer to your local bomb threat management plan for evacuation criteria***

**BOMB THREAT CHECKLIST**

DATE:   TIME:

TIME CALLER HUNG UP:   PHONE NUMBER WHERE CALL RECEIVED:

**Ask Caller:**

- Where is the bomb located? (building, floor, room, etc.)
- When will it go off?
- What does it look like?
- What kind of bomb is it?
- What will make it explode?
- Did you place the bomb? Yes No
- Why?
- What is your name?

**Exact Words of Threat:**

**Information About Caller:**

- Where is the caller located? (background/level of noise)
- Estimated age:
- Is voice familiar? If so, who does it sound like?
- Other points:

| Caller's Voice | Background Sounds | Threat Language |
|---|---|---|
| ☐ Female | ☐ Animal noises | ☐ Incoherent |
| ☐ Male | ☐ House noises | ☐ Message read |

# ឧបសម្ព័ន្ធE – បញ្ជីពិនិត្យផែនការសកម្មភាពអាសន្ន ផ្តល់ដោយOSHA

| បញ្ហាទូទៅ | | |
|---|---|---|
| ☐ | តើផែនការ មានគិតគូរពីស្ថានភាពអាសន្នទាំងអស់ដែលបង្កដោយធម្មជាតិឬបង្កដោយមនុស្ស ដែលអាចរំខានដល់កន្លែងការងាររបស់អ្នកឬទេ ? | ប្រភពសាមញ្ញនៃស្ថានភាពអាសន្ន ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងផែនការសកម្មភាពអាសន្ន រួមមាន អគ្គិភ័យ ការផ្ទុះ ទឹកជំនន់ ព្យុះសង្ឃរា ព្យុះកំបុតត្បូង ការបញ្ចេញសារធាតុពុល គ្រោះថ្នាក់វិទ្យុសកម្មនិងជីវសាស្ត្រ ចលាចលស៊ីវិល និងអំពើហិង្សានៅកន្លែងការងារ។ |
| ☐ | តើផែនការ មានគិតគូរពីប្រភពខាងក្នុងដែលអាចមានទាំងអស់នៃស្ថានភាពអាសន្ន ដែលអាចរំខានដល់កន្លែងការងាររបស់អ្នកឬទេ ? | ធ្វើការប៉ាន់ប្រមាណគ្រោះថ្នាក់អន្តរាយនៅកន្លែងការងារ ដើម្បីកំណត់អត្តសញ្ញាណគ្រោះថ្នាក់អន្តរាយផ្នែករូបឬផ្នែកគីមីដែលអាចមាន និងដែលអាចបង្កឲ្យមានស្ថានភាពអាសន្ន។ |
| ☐ | តើផែនការ មានគិតគូរពីផលប៉ះពាល់នៃស្ថានភាពអាសន្នខាងក្នុងនិងខាងក្រៅទាំងនេះលើដំណើរការរបស់កន្លែងការងារឬទេ ហើយតើការឆ្លើយតបសមស្របនឹងកន្លែងការងារឬទេ ? | រកនឹកពីសេណារីយ៉ូក្នុងករណីអាក្រក់បំផុត។ សួរខ្លួនឯងថា តើអ្នកនឹងធ្វើអ្វី តើផលប៉ះពាល់ដែលអាចកើតមានលើដំណើរការរបស់អ្នកជាអ្វី និង តើអ្វីជាការឆ្លើយតបដែលសមស្របនឹងឧបករណ៍។ |

| | | |
|---|---|---|
| ☐ | តើផែនការ<br>មានបញ្ចូលបញ្ជីមន្ត្រីសំខាន់ៗនិងមធ្យោបាយទាក់ទងរបស់ពួកគេ<br>ក៏ដូចជាមធ្យោបាយទាក់ទងរបស់អ្នកឆ្លើយតបបឋម ទីភ្នាក់ងារ<br>និងអ្នកម៉ៅការក្នុងមូលដ្ឋាន ឬទេ ? | ធ្វើបច្ចុប្បន្នភាពបញ្ជីមធ្យោបាយទាក់ទងសំខាន់ៗរបស់អ្នក ហើយប្រមើលត្រៀមឲ្យមានប្រព័ន្ធទាក់ទងអាសន្ន ដូចជាទូរសព្ទដៃឬវិទ្យុចល័ត ដើម្បីឲ្យការទាក់ទងជាមួយសមត្ថកិច្ច នាយកដ្ឋានពន្លត់អគ្គិភ័យក្នុងមូលដ្ឋាន និងបុគ្គលផ្សេងទៀត អាចប្រព្រឹត្តទៅដោយរលូន។ |
| ☐ | តើផែនការ មានបញ្ចូលឈ្មោះ មុខតំណែង នាយកដ្ឋាន<br>និងលេខទូរសព្ទរបស់បុគ្គលដែលត្រូវទាក់ទងដើម្បីទទួលបានព័ត៌មានបន្ថែម<br>ឬការពន្យល់ពីភារកិច្ចនិងទំនួលខុសត្រូវនៅក្រោមផែនការ ឬទេ ? | រាយឈ្មោះ និងមធ្យោបាយទាក់ទងរបស់បុគ្គលទទួលខុសត្រូវក្នុងការអនុវត្តផែនការ។ |
| ☐ | តើផែនការ<br>មានបញ្ជាក់ពីរបៀបដែលដំណើរការជួយសង្គ្រោះនឹងត្រូវបានអនុវត្ត ឬទេ ? | លុះត្រាតែអ្នកជានិយោជកធំដែលចាត់ចែងសម្ភារនិងដំណើរការគ្រោះថ្នាក់អន្តរាយ<br>ឬអ្នកមានបុគ្គលិកធ្វើការជាប្រចាំនៅក្នុងស្ថានភាពគ្រោះថ្នាក់អន្តរាយ<br>អ្នកប្រហែលជាត្រូវពឹងផ្អែកលើធនធានសាធារណៈក្នុងមូលដ្ឋាន<br>ដូចជានាយកដ្ឋានពន្លត់អគ្គិភ័យដែលត្រូវបានបណ្តុះបណ្តាល បំពាក់ឧបករណ៍<br>និងទទួលស្គាល់ឲ្យធ្វើការជួយសង្គ្រោះ។<br>ត្រូវប្រាកដថានាយកដ្ឋានឬទីភ្នាក់ងារខាងក្រៅដែលត្រូវបានកំណត់នៅក្នុងផែនការរបស់អ្នក<br>ត្រូវបានត្រៀមដើម្បីឆ្លើយតបដូចបានគ្រោងនៅក្នុងផែនការរបស់អ្នក។<br>បុគ្គលដែលមិនបានទទួលការបណ្តុះបណ្តាល អាចបង្កគ្រោះថ្នាក់ដល់ខ្លួនឯង<br>និងអ្នកដែលពួកគេកំពុងព្យាយាមជួយសង្គ្រោះ។ |

| | | |
|---|---|---|
| ☐ | តើផែនការ<br>មានបញ្ជាក់ពីរបៀបដែលជំនួយផ្នែកវេជ្ជសាស្ត្រនឹងត្រូវបានផ្តល់ឲ្យ ឬទេ ? | និយោជកតូចៗភាគច្រើន មិនមានកម្មវិធីវេជ្ជសាស្ត្រផ្ទៃក្នុងផ្លូវការទេ<br>ហើយជំនួសមកវិញដោយការណាត់ជួបជាមួយគ្លីនិកឬកន្លែងព្យាបាលដែលនៅក្បែរៗ<br>ដើម្បីដោះស្រាយស្ថានភាពអាសន្ន។ បើគិលានដ្ឋាន គ្លីនិក ឬមន្ទីរពេទ្យមិននៅជិតកន្លែងការងាររបស់អ្នកទេ<br>ត្រូវប្រាកដថាបុគ្គលនៅកន្លែងផ្ទាល់ មានការបណ្តុះបណ្តាលគ្រប់គ្រាន់ក្នុងការផ្តល់ជំនួយបឋម។<br>កាកបាទក្រហមអាមេរិក អ្នកផ្តល់សេវាធានារ៉ាប់រងមួយចំនួន ក្រុមប្រឹក្សាសុវត្ថិភាពក្នុងមូលដ្ឋាន<br>នាយកដ្ឋានពន្លត់អគ្គិភ័យ ឬធនធានផ្សេងៗទៀត ប្រហែលជាអាចផ្តល់ការបណ្តុះបណ្តាលនេះ។<br>ការព្យាបាលរបួសធ្ងន់ធ្ងរ គួរតែចាប់ផ្តើមក្នុងរយៈពេល **3** ទៅ **4** នាទីបន្ទាប់ពីគ្រោះថ្នាក់។<br>ពិគ្រោះជាមួយគ្រូពេទ្យដើម្បីកុម្ម៉ង់សម្ភារផ្គត់ផ្គង់ជំនួយបឋមដែលសមស្របសម្រាប់ស្ថានភាពអាសន្ន។<br>បង្កើតទំនាក់ទំនងជាមួយសេវាកម្មរថយន្តសង្គ្រោះបន្ទាន់ក្នុងមូលដ្ឋាន<br>ដើម្បីឲ្យការដឹកជញ្ជូនមានភាពត្រៀមរួចរាល់សម្រាប់ស្ថានភាពអាសន្ន។ |
| ☐ | តើផែនការ<br>មានកំណត់ពីរបៀបឬកន្លែងដែលអាចទទួលបានព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលិកនៅពេលមានស្ថានភាពអាសន្ន? | ក្នុងស្ថានភាពអាសន្ន<br>វាអាចមានសារៈសំខាន់ក្នុងការមានលទ្ធភាពចូលប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនសំខាន់ៗរបស់បុគ្គលិករបស់អ្នក។<br>វារួមបញ្ចូលទាំងលេខទូរសព្ទផ្ទះ ឈ្មោះ លេខទូរសព្ទរបស់ញាតិសាច់ជិត និងព័ត៌មានវេជ្ជសាស្ត្រ។ |
| **គោលការណ៍និងនិតិវិធីនៃការជម្លៀស** | | |
| ☐ | តើផែនការ<br>មានកំណត់ពីលក្ខខណ្ឌដែលតម្រូវឲ្យមានការជម្លៀស ឬទេ ? | ផែនការ គួរតែកំណត់ស្ថានភាពដែលនឹងតម្រូវឲ្យមានការជម្លៀសចេញពីកន្លែងការងារ។ វាអាចរួមទាំងអគ្គិភ័យ ការរញ្ជួយដី ឬការកំពប់សារធាតុគីមី។ វិសាលភាពនៃការជម្លៀសដែលចាំបាច់ អាចមានភាពខុសប្លែកគ្នាទៅតាមប្រភេទនៃគ្រោះថ្នាក់អន្តរាយផ្សេងៗ។ |
| ☐ | តើផែនការ<br>មានកំណត់ពីខ្សែសង្វាក់បញ្ជាដែលច្បាស់លាស់<br>និងមានចាត់តាំងបុគ្គលដែលមានសិទ្ធិអំណា | វាជារឿងធម្មតាទេក្នុងការជ្រើសរើសបុគ្គលទទួលខុសត្រូវ<br>ឲ្យដឹកនាំនិងសម្របសម្រួលផែនការអាសន្ននិងការជម្លៀសរបស់អ្នក។<br>វាជារឿងសំខាន់ដែលបុគ្គលិកត្រូវដឹងថានរណាជាអ្នកសម្របសម្រួល<br>និងត្រូវដឹងថាបុគ្គលនោះមានសិទ្ធិអំណាចក្នុងការសម្រេចចិត្តនៅពេលមានស្ថានភាពអាសន្ន។ អ្នកសម្របសម្រួល |

| | | |
|---|---|---|
| | ចបញ្ហាឲ្យមានការជម្លៀសឬការផ្អាច់ដំណើរការ ឬទេ ? | ទទួលខុសត្រូវក្នុងការប៉ាន់ប្រមាណស្ថានការណ៍ដើម្បីកំណត់ថា តើមានស្ថានភាពអាសន្នដែលទាមទារឲ្យដាក់ដំណើរការនីតិវិធីអាសន្ន ចាត់ការនីតិវិធីអាសន្ន ជូនដំណឹងនិងសម្របសម្រួលជាមួយសេវាកម្មអាសន្នខាងក្រៅ និងដឹកនាំការបិទរបស់របរប្រើប្រាស់ឬដំណើរការរោងចក្រប្រសិនបើចាំបាច់។ |
| ☐ | តើផែនការ មានបញ្ជាក់ពីប្រភេទនៃសកម្មភាពដែលរំពឹងទុកពីបុគ្គលិកផ្សេងៗសម្រាប់ប្រភេទនៃស្ថានភាពអាសន្នដែលអាចកើតមាន ឬទេ ? | ផែនការ អាចបញ្ជាក់នូវសកម្មភាពផ្សេងៗសម្រាប់បុគ្គលិក អាស្រ័យលើស្ថានភាពអាសន្ន។ ឧទាហរណ៍ និយោជិតប្រហែលជាចង់ឲ្យបុគ្គលិកជួបជុំគ្នានៅក្នុងតំបន់មួយនៃកន្លែងការងារ ប្រសិនបើត្រូវបានគំរាមដោយព្យុះកំបុតត្បូងឬការរញ្ជួយដី ប៉ុន្តែចង់ឲ្យជម្លៀសទៅទីតាំងខាងក្រៅអំឡុងពេលមានអគ្គិភ័យ។ |
| ☐ | តើផែនការ មានចាត់តាំងថានរណា (បើមាន) នឹងនៅបិទដំណើរការសំខាន់ៗនៅក្នុងអំឡុងពេលជម្លៀស ឬទេ ? | គិតគូរពីការបញ្ចូលទីតាំងនៃកន្លែងដែលត្រូវបិទរបស់របរប្រើប្រាស់ ដូចជារបស់របរប្រើប្រាស់អគ្គិសនីនិងឧស្ម័នសម្រាប់កន្លែងទាំងមូលឬមួយផ្នែកនៃកន្លែង។ បុគ្គលទាំងអស់ដែលនៅក្រោយដើម្បីបិទប្រព័ន្ធឬរបស់របរប្រើប្រាស់សំខាន់ៗ ត្រូវតែមានសមត្ថភាពកត់សម្គាល់ថាតើពេលណាដែលត្រូវបោះបង់ចោលដំណើរការឬភារកិច្ច ហើយជម្លៀសខ្លួនចេញ។ |
| ☐ | តើផែនការ មានគ្រោងផ្លូវជម្លៀសនិងច្រកចេញជាក់លាក់ឬទេ ហើយតើវាត្រូវបានបិទបង្ហាញនៅកន្លែងការងារដែលបុគ្គលិកទាំងអស់អាចចូលមើលបានដោយងាយស្រួលឬទេ ? | និយោជកភាគច្រើន បង្កើតផែនទីពីដ្យាក្រាមប្លង់ជាន់ ដោយមានសញ្ញាព្រួញបញ្ជាក់ពីការបែងចែកផ្លូវចេញ។ ផែនទីទាំងនេះ គួរតែមានបញ្ចូលទីតាំងនៃច្រកចេញ ចំណុចជួបជុំ និងឧបករណ៍ (ដូចជាបំពង់ពន្លត់អគ្គិភ័យ កញ្ចប់ជំនួយបឋម និងកញ្ចប់កំពប់) ដែលអាចនឹងត្រូវការក្នុងស្ថានភាពអាសន្ន។ ផ្លូវចេញគួរតែមានដាក់សញ្ញាសម្គាល់ច្បាស់ៗនិងមានភ្លើងបំភ្លឺល្អ ធំទូលាយសមល្មមក្នុងការផ្ទុកចំនួនបុគ្គលិកជម្លៀស មិនមានឧបសគ្គនិងស្អាតគ្មានកម្ទេចកម្ទីគ្រប់ពេលវេលា និងមិនធ្វើឲ្យបុគ្គលិកជម្លៀសមានគ្រោះថ្នាក់អន្តរាយបន្ថែមនោះទេ។ |
| ☐ | តើផែនការ មានបញ្ជាក់ពីនីតិវិធីសម្រាប់ជួយមនុស្សក្នុងអំឡុងពេលជម្លៀស ជាពិសេសជនមានពិការភាព ឬ | និយោជកជាច្រើន ចាត់តាំងអ្នកយាមការជម្លៀសដើម្បីជួយផ្លាស់ទីបុគ្គលិកពីតំបន់គ្រោះថ្នាក់ទៅតំបន់សុវត្ថិភាពក្នុងស្ថានភាពអាសន្ន។ ជាទូទៅ អ្នកយាមម្នាក់សម្រាប់បុគ្គលិក20នាក់ គឺគ្រប់គ្រាន់ ហើយចំនួនអ្នកយាមដែលសមរម្យ គួរតែមាននៅគ្រប់ពេលក្នុងម៉ោងធ្វើការ។ អ្នកយាមអាចនឹងទទួលខុសត្រូវក្នុងការពិនិត្យមើលការិយាល័យនិងបន្ទប់ទឹក |

| | | |
|---|---|---|
| | អ្នកដែលមិនចេះភាសាអង់គ្លេស ឬទេ? | មុននឹងក្លាយជាមនុស្សចុងក្រោយដែលចាកចេញពីតំបន់មួយ ព្រមទាំងធានាថាទ្វារអគ្គិភ័យត្រូវបានបិទនៅពេលចេញ។ បុគ្គលិកដែលត្រូវបានចាត់តាំងឲ្យជួយក្នុងនីតិវិធីជម្លៀសអាសន្ន គួរតែត្រូវបានបណ្តុះបណ្តាលនៅក្នុងប្លង់កន្លែងការងារទាំងមូល និងផ្លូវរត់គេចជំនួស។ បុគ្គលិកដែលត្រូវបានចាត់តាំងឲ្យជួយក្នុងស្ថានភាពអាសន្ន គួរតែប្រាប់ឲ្យដឹងពីបុគ្គលិកដែលមានតម្រូវការពិសេស (ដែលអាចនឹងត្រូវការជំនួយបន្ថែមក្នុងអំឡុងពេលជម្លៀស) របៀបប្រើប្រាស់ប្រព័ន្ធជួយមិត្ត និងតំបន់គ្រោះថ្នាក់អន្តរាយនានាដើម្បីជៀសមិនទៅក្នុងអំឡុងពេលជម្លៀសអាសន្ន។ |
| ☐ | តើផែនការ មានកំណត់ពីតំបន់ជួបជុំមួយឬច្រើន (ទៅតាមការចាំបាច់សម្រាប់ប្រភេទស្ថានភាពអាសន្នផ្សេងៗ) ដែលបុគ្គលិកនឹងប្រមូលផ្តុំគ្នា និងមានកំណត់វិធីសាស្ត្រសម្រាប់កត់បញ្ជីបុគ្គលិកទាំងអស់ ឬទេ? | ការកត់បញ្ជីបុគ្គលិកទាំងអស់ក្រោយពីជម្លៀស ជារឿងដ៏មានមានសារៈសំខាន់។ ភាពច្របូកច្របល់នៅក្នុងតំបន់ជួបជុំ អាចនាំឲ្យមានភាពយឺតយ៉ាវដល់ការជួយសង្គ្រោះអ្នកដែលជាប់នៅក្នុងអគារ ឬអាចនាំឲ្យមានដំណើរការស្វែងរកជួយសង្គ្រោះដែលមិនចាំបាច់និងមានគ្រោះថ្នាក់។ ដើម្បីធានាបាននូវការកត់បញ្ជីបុគ្គលិករបស់អ្នកបានលឿនបំផុត និងត្រឹមត្រូវបំផុត ត្រូវគិតគូររាប់ចំនួនមនុស្សបន្ទាប់ពីការជម្លៀស។ ឈ្មោះនិងទីតាំងដឹងចុងក្រោយរបស់អ្នកដែលមិនត្រូវបានកត់បញ្ជី គួរតែបញ្ជូនបន្តទៅឲ្យមន្ត្រីទទួលបន្ទុក។ |
| ☐ | តើផែនការ មានបញ្ជាក់ពីរបៀបដែលភ្ញៀវនឹងត្រូវបានកត់បញ្ជីនិងត្រូវបានជួយនៅក្នុងការជម្លៀស ឬទេ? | និយោជកមួយចំនួន តម្រូវឲ្យភ្ញៀវនិងអ្នកម៉ៅការទាំងអស់ស៊ីញ៉េចូល នៅពេលពួកគេចូលកន្លែងការងារនោះ។ ម្ចាស់ផ្ទះ ឬអ្នកយាមតំបន់ (បើមាន) ជារឿយៗត្រូវបានផ្តល់ភារកិច្ចឲ្យជួយភ្ញៀវ និងអ្នកម៉ៅការឲ្យជម្លៀសចេញបានដោយសុវត្ថិភាព។ |

| **ការរាយការណ៍ពីស្ថានភាពអាសន្ន និង ការប្រកាសប្រាប់បុគ្គលិកក្នុងស្ថានភាពអាសន្ន** | | |
|---|---|---|
| ☐ | តើផែនការ មានកំណត់ពីវិធីសាស្ត្រចង់បាន | ការតេទៅលេខ911 គឺជាវិធីសាស្ត្រសាមញ្ញមួយសម្រាប់ការរាយការណ៍ពីស្ថានភាពអាសន្ន បើមានប្រើអ្នកឆ្លើយតបខាងក្រៅ។ លេខផ្ទៃក្នុង អាចនឹងត្រូវបានប្រើ |

| | | |
|---|---|---|
| | សម្រាប់ការរាយការណ៍ពីអគ្គិភ័យនិងស្ថានភាពអាសន្នផ្សេងទៀត ឬទេ ? | ហើយជូនកាលត្រូវបានភ្ជាប់ទៅប្រព័ន្ធឆ្លើយឆ្លងគ្នា ដើម្បីឲ្យមានការប្រកាសកូដ។ ក្នុងករណីខ្លះ បុគ្គលិកត្រូវបានស្នើឲ្យដាក់ដំណើរការប្រអប់ទាញចុះដោយដៃ ឬប្រព័ន្ធកណ្ដឹងរោទ៍ផ្សេងទៀត។ |
| ☐ | តើផែនការ មានរៀបរាប់ពីវិធីសាស្ត្រដែលប្រើសម្រាប់ប្រកាសប្រាប់បុគ្គលិក រួមទាំងបុគ្គលិកមានពិការភាពផងដែរ ឲ្យជម្លៀស ឬធ្វើសកម្មភាពផ្សេងទៀត ឬទេ ? | ត្រូវប្រាកដថាកណ្ដឹងរោទ៍មានលក្ខណៈប្លែកពីគេ ហើយបុគ្គលិកទាំងអស់អាចដឹងបាន។ សំឡេងចុចស៊ីផ្លេបន្តជាប់ៗគ្នា ឬប្រភេទសំឡេងកណ្ដឹងរោទ៍ផ្សេងៗ (ដូចជាកណ្ដឹង ឬស៊ីផ្លេ) អាចប្រើដើម្បីជាសញ្ញានៃការឆ្លើយតប ឬសកម្មភាពផ្សេងៗពីបុគ្គលិក។ គិតគូរបង្កើតប្រព័ន្ធទាក់ទងអាសន្នដែលអាចធ្វើបាន ដូចជាប្រព័ន្ធផ្សព្វផ្សាយសាធារណៈសម្រាប់ការផ្សាយព័ត៌មានអាសន្នដល់បុគ្គលិក។ ល្អបំផុតគឺកណ្ដឹងរោទ៍ នឹងអាចត្រូវបានឮឬឃើញ ឬបើមិនដូច្នេះទេ អាចយល់បានដោយមនុស្សគ្រប់គ្នានៅកន្លែងការងារ រួមទាំងអ្នកខ្វាក់ភ្នែក ឬអ្នកថ្លង់ផងដែរ។ បើមិនដូច្នេះទេ ត្រូវតែផ្ដល់ភារកិច្ចឲ្យអ្នកយាមជាន់ឬបុគ្គលផ្សេងទៀត ឲ្យធានាថាបុគ្គលិកទាំងអស់ត្រូវបានជូនដំណឹង។ គិតគូរផ្ដល់ការផ្គត់ផ្គង់ថាមពលជំនួយ ក្នុងពេលដាច់ភ្លើង។ |

| **ការបណ្ដុះបណ្ដាលនិងការហ្វឹកហ្វឺនបុគ្គលិក** | | |
|---|---|---|
| ☐ | តើផែនការ មានកំណត់ពីរបៀប និងពេលវេលាដែលបុគ្គលិកនឹងត្រូវបានបណ្ដុះ បណ្ដាលដើម្បីឲ្យយល់ពីប្រភេទនៃស្ថានភាពអាសន្នដែលអាចនឹងកើតឡើង ទំនួលខុសត្រូវនិងសកម្មភាពរបស់ពួកគេ ឬទេ ? | បណ្ដុះបណ្ដាលបុគ្គលិកនៅពេលអ្នកបង្កើតផែនការដំបូងរបស់អ្នក និងនៅពេលជួលបុគ្គលិកថ្មីឲ្យចូលធ្វើការ។<br>បណ្ដុះបណ្ដាលបុគ្គលិកឡើងវិញ<br>នៅពេលដែលផែនការរបស់អ្នកប្រែប្រួលដោយសារការផ្លាស់ប្ដូរប្លង់កន្លែងឬការរចនាកន្លែង នៅពេលដែលឧបករណ៍ថ្មី គ្រោះថ្នាក់អន្តរាយថ្មី ឬប្រតិបត្តការថ្មី ត្រូវបានដាក់បញ្ចូល ដែលនឹងប៉ះពាល់ដល់ផ្លូវជម្លៀស<br>ឬនៅពេលដែលប្រភេទថ្មីនៃគ្រោះថ្នាក់អន្តរាយ ត្រូវបានដាក់បញ្ចូល ដែលតម្រូវឲ្យមានសកម្មភាពពិសេស។<br>ការបណ្ដុះបណ្ដាលទូទៅសម្រាប់បុគ្គលិករបស់អ្នក គួរតែមានបញ្ជាក់ពី៖<br>· តួនាទី និងទំនួលខុសត្រូវរបស់បុគ្គលម្នាក់ៗ<br>· ការគំរាមកំហែង គ្រោះថ្នាក់អន្តរាយ និងសកម្មភាពការពារ<br>· ការជូនដំណឹង ការព្រមាន និងនីតិវិធីទាក់ទង |

| | | |
|---|---|---|
| | | · នីតិវិធីឆ្លើយតបអាសន្ន<br>· ការជម្លៀស ជម្រក និងនីតិវិធីកត់បញ្ជី<br>· ទីតាំង និងការប្រើប្រាស់ឧបករណ៍អាសន្នសាមញ្ញ<br>· នីតិវិធីផ្តាច់គ្រាអាសន្ន<br>អ្នកក៏ប្រហែលជាត្រូវផ្តល់ការបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិករបស់អ្នកផងដែរ (ឧទាហរណ៍៖ នីតិវិធីជំនួយបឋម ការប្រើប្រាស់បំពង់ពន្លត់អគ្គិភ័យចល័តបាន) អាស្រ័យលើទំនួលខុសត្រូវនៅក្នុងផែនការរបស់អ្នក។ |
| ☐ | តើផែនការ មានបញ្ជាក់ពីរបៀប និងពេលវេលាដែលការបណ្តុះបណ្តាលឡើងវិញនឹងត្រូវធ្វើឡើង ឬទេ? | ប្រសិនបើការបណ្តុះបណ្តាលមិនត្រូវបានពង្រឹងទេនោះ វានឹងត្រូវបានបំភ្លេចចោល។ គិតគូរបណ្តុះបណ្តាលបុគ្គលិកឡើងវិញជារៀងរាល់ឆ្នាំ។ |
| ☐ | តើផែនការ មានបញ្ជាក់ថា តើការហ្វឹកហ្វឺននឹងត្រូវធ្វើឡើង ហើយធ្វើឡើងញឹកញាប់ប៉ុណ្ណា ឬទេ? | នៅពេលដែលអ្នកបានពិនិត្យឡើងវិញនូវផែនការសកម្មភាពអាសន្ន ជាមួយបុគ្គលិករបស់អ្នក ហើយគ្រប់គ្នាបានទទួលការបណ្តុះបណ្តាលដែលសមស្រប វាជាគំនិតល្អក្នុងការធ្វើការហ្វឹកហ្វឺនឲ្យបានញឹកញាប់ទៅតាមការចាំបាច់។ បញ្ចូលធនធានខាងក្រៅ ដូចជានាយកដ្ឋានពន្លត់អគ្គភ័យ និងនាយកដ្ឋានប៉ូលីស នៅពេលដែលអាចធ្វើទៅបាន។ ក្រោយការហ្វឹកហ្វឺននីមួយៗ ប្រមូលផ្តុំជួរគ្រប់គ្រងនិងបុគ្គលិក ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការហ្វឹកហ្វឺន។ កំណត់ពីចំណុចខ្លាំង និងចំណុចខ្សោយនៃផែនការរបស់អ្នក ហើយធ្វើការកែលម្អវា។ |

# ឧបសម្ព័ន្ធF – ការចែកចាយផែនការ និង ប្រវត្តិនៃការកែសម្រួល

## ការចែកចាយផែនការ និង ការចូលប្រើ

ផែនការ នឹងត្រូវបានចែកចាយទៅឲ្យសមាជិកក្រុមការងារឆ្លើយតបអាសន្ន និងប្រធាននាយកដ្ឋានផ្សេងៗ។ ច្បាប់ចម្លងមេនៃឯកសារ គួរតែរក្សាទុកដោយប្រធានក្រុមការងារឆ្លើយតបអាសន្ន។ ផែនការ នឹងមានសម្រាប់ទុកឲ្យបុគ្គលិកទាំងអស់ពិនិត្យឡើងវិញ។ ច្បាប់ចម្លងច្រើនច្បាប់ គួរតែត្រូវបានរក្សាទុក ដើម្បីធានាថាសមាជិកក្រុមការងារអាចពិនិត្យឡើងវិញនូវតួនាទី ទំនួលខុសត្រូវ ភារកិច្ច និងព័ត៌មានយោងបានឆាប់រហ័ស នៅពេលដែលក្រុមការងារត្រូវបានដាក់ឲ្យដំណើរការ។ ច្បាប់ចម្លងអេឡិចត្រូនិចនៃផែនការ គួរតែត្រូវបានរក្សាទុកនៅលើគេហទំព័រដែលមានសុវត្ថិភាព និងអាចចូលប្រើបាន ដែលនឹងអាចឲ្យសមាជិកក្រុមការងារចូលប្រើបាន ប្រសិនបើដាច់ស៊ើវើមេរបស់ក្រុមហ៊ុន។

## ប្រវត្តិនៃការកែសម្រួល

| ការកែសម្រួល | កាលបរិច្ឆេទ | ខ្លឹមសារនៃការផ្លាស់ប្តូរ | ការផ្តល់ការអនុញ្ញាត |
|---|---|---|---|
| 1 | | | |
| 2 | | | |
| 3 | | | |
| 4 | | | |
| 5 | | | |
| 6 | | | |
| 7 | | | |